# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៣ ខែមិថុនា លេខ ៦

ព. ស. ២៤៩៤ — គ. ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ពុទ្ធសាសនានិងគ្រិស្តសាសនា (សន្និសីទ លោក.វជ្ជបណ្ឌិតមិត្តគូត) (តមក) | លោក ភ៊យ - ប៊ុក | ៤០៣ |
| ពន្លឺអាស៊ីទ្វីប (តមក) | លោក ភ៊យ - ប៊ុក | ៤០៩ |
| ពុទ្ធសាសនានៅប្រទេសជប៉ុន | លោក ប៊ូ - ប៊ូ | ៤១៦ |
| សារណកថា | លោកអាចារ្យ ឯង - ស មិទ្ធិ | ៤២៤ |

**ផ្នែកអក្សរសាស្ត្រ**

| | | |
|---|---|---|
| ការបណ្ដុះនិស្ស័យ (តមក) | ព្រះមហាឧត្តមវិជ្ជា ប៊ុត - ប៉ម | ៤៣២ |
| អឹឡេណក - សំម្បុណ្ណ | លោកផេង - ជ្រឹវ | ៤៤២ |
| សព្ទបារាំងប្រែជាខ្មែរ (តមក) | ពុទ្ធសាសនបណ្ឌិត្យ | ៤៥២ |
| រឿងសាមកុក (តមក) | ឧកញ៉ា ទួ - កន | ៤៥៩ |
| ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) | ឧកញ៉ា ឈឹម - ក្រសេម | ៤៧៣ |

**កំណត់និងប្រវត្តិការណ៍**

| | | |
|---|---|---|
| បញ្ជីព្រះនាមចៅអធិការដែលទើបតាំងថ្មី (តមក) | ក្រសួងធម្មការ | ៤៧៩ |



មួយឆ្នាំមាន ១២ សៀវភៅ ថ្លៃជាវ ១៤៥៛,០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES

### PARTIE RELIGIEUSE

| | | Pages |
|---|---|---|
| Bouddhisme et Christianisme (Conférence du Docteur A. Migot) (suite) | *M. RAY-BUC* | 403 |
| La Lumière de l'Asie (suite) | *M. RAY-BUC* | 409 |
| Le bouddhisme au Japon | *M. BOU-PO* | 416 |
| SARANAKATHA | *Achar NONG-SAMITH* | 424 |

### PARTIE LITTERAIRE

| | | |
|---|---|---|
| Education morale (suite) | *Préah Moha PEUNG-PAM* | 432 |
| Histoire d'Hélèna-Simiana | *M. PHENG-CHRIEU* | 442 |
| Erratum des mots traduits par la Commission Culturelle | *M. MENH-NAKRY* | 452 |
| Histoire de SAMKOK (suite) | *Oknha NOU-KAN* | 459 |
| Histoire du Royaume du Cambodge (suite | *Oknha CHHIM-KRASEM* | 473 |

### NOTES ET CHRONIQUES

| | | |
|---|---|---|
| Nomination des Chau-Athicar.... (suite) | *Ministère des Cultes* | 479 |

Prix d'abonnement annuel comprenant 12 numéros: 145$00

# ពុទ្ធសាសនានិងគ្រិស្តសាសនា

## សន្និសិទលោកវេជ្ជបណ្ឌិត មីគូត៍

លោក ក៉យ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យភ្នំពេញ

ប្រែពីទស្សនាវដ្ដី "ហ្វ្រង់អាស៊ី" ខែមិថុនា ឆ្នាំ ១៩៥០

(តមក)

---

ចំណែកខាងបូព៌ាប្រទេស, ពួកទស្សនវិទូជាគ្រូខាងសាសនាដែលមានជីវិតរស់នៅជានិរន្តរកាលចំពោះលទ្ធិរបស់ខ្លួន មានសាវកហោមរោមជាបរិវារ ដែលមានប្រាជ្ញាប្រព្រឹត្តប្រតិបត្តិទៅតាមលទ្ធិដែលខ្លួនបានសិក្សា ។ លទ្ធិនេះ គឺមិនមែនជាការស្វះស្វែងខាងផ្លូវប្រាជ្ញាជាធម្មតាទេ គឺជាលទ្ធិដែលមានតម្លៃត្រង់ការប្រតិបត្តិដើម្បីឲ្យសម្រេចនូវលទ្ធផល ។ តើមានផលប្រយោជន៍អ្វីត្រង់ការសួរថា ព្រះពុទ្ធសាសនាជាទស្សនវិជ្ជា ឬជាសាសនវិជ្ជា? ព្រះពុទ្ធសាសនាជាផ្លូវមួយ, ជាអរិយមគ្គមួយ, មគ្គដែលនាំឲ្យព្រះសម្មាសម្ពុទ្ធត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ, វិធីប្រតិបត្តិមួយដើម្បីនឹងសម្រេចឲ្យបានលទ្ធផល មធ្យោបាយមួយដើម្បីនឹងទៅកាន់ស្ថានរំលត់ទុក្ខទាំងពួង ដោយបំពេញកិច្ចការខាងផ្លូវធម៌ ព្យាយាមយ៉ាងម៉ឺងម៉ាត់ ។

ដែលនាំឲ្យយល់ថា ព្រះសម្មាសម្ពុទ្ធជាអ្នកមិច្ឆាទិដ្ឋិចំពោះអាទិទេព (Atbée) ដោយហេតុថាព្រះអង្គទ្រង់មិនដែលបានវិសជ្ជនាទៅកាន់សាវក

ដែលមានពាក្យបុច្ឆាទៅកាន់ព្រះអង្គ អំពីដើមកំណើតនៃពិភពលោក, ធម្មជាតិនៃអាទិទេព, សភាពដែលមានជីវិតរស់នៅក្នុងស្ថានព្រះនិព្វាន ។ គឺមិនមែនថាព្រះអង្គមិនជ្រាបច្បាស់នូវបញ្ហាទាំងនោះទេ តែដោយព្រះអង្គទ្រង់បានត្រាស់សម្មាសម្ពោធិញ្ញាណ ទ្រង់បានយល់ច្បាស់នូវធម្មជាតិនៃវត្ថុទាំងអស់គ្មានសេសសល់ តែទ្រង់ព្រះតម្រិះថាការសិក្សាចំពោះវិជ្ជាទាំងនេះ មិនជាប្រយោជន៍ មិនអាចនាំសត្វលោកឲ្យចាកចេញពីសេចក្តីទុក្ខបានឡើយ ។ ព្រះអង្គមិនមែនទូន្មានសត្វឲ្យរៀនសូត្រនូវកម្មវត្ថុនៃវិជ្ជាទាំងនោះ តែទ្រង់ឲ្យរិះរកមធ្យោបាយ ដើម្បីនឹងដំណើរការឲ្យសម្រេចដល់នូវវិជ្ជានោះគឺមគ្គសច្ច, ដោយទ្រង់ព្រះយោបល់ថា មគ្គសច្ចនេះ អាចបង្ហាញឲ្យពួកសាវកដោះស្រាយនូវបញ្ហាខាងលើឲ្យបានសព្វគ្រប់ ។

ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះបន្ទូលជាញឹកញយអំពីអាទិទេពដែលប្រទេសឥណ្ឌាបាននិយមគោរពក្នុងកាលនោះ; ព្រះអង្គទ្រង់យល់ថា ជាទេវតាជាន់ខ្ពស់ស្ថិតនៅនាស្ថានដ៏ឧត្តម តែត្រូវនៅក្នុងអំណាចនៃអនិច្ចតាធម៌នឹងកម្មដូចយើងខានមិនបាន ។ ហេតុម្តេចក៏បានជាសូមពារញឹកញយអំពីអាទិទេពមួយដែលស្ថិតនៅក្រៅពិភពលោក ហើយអាទិទេពនេះថាជាអ្នកបង្កើតនូវលោកដែលមានសភាពទទេ ថាមិនមែនកើតមកពីទទេទេ? (គឺថាវត្ថុទាំងអស់មិនដែលកើតមកឯង ៗ ទេ តែវត្ថុ

ដែលមានមកក្នុងលោក គឺមានមកពីអតីតកាលយូរណាស់មកហើយ ex-nihilis ) ។ យើងមិនអាចដឹងបាននូវបុព្វហេតុនៃលោក ; ការស្វែងរកឬស្រាវជ្រាវនូវបញ្ហានេះជាការឥតប្រយោជន៍, មិនអាចនឹងជួយយើងឲ្យបានសម្រេចទៅតាមវត្ថុបំណងរបស់យើងឡើយ កិច្ចដែលត្រូវធ្វើគឺការតស៊ូនឹងទុក្ខ, ការចេញចាកទុក្ខ នឹងការដែលមានប្រាជ្ញាភ្លឺស្វាង ( សម្រេចនូវធម៌ដ៏ប្រពៃ ) ។

តែនៅបាំងពីខាងក្រោយអហេតុកលទ្ធិ ( ធម៌ជាអហេតុក : ជនសាមញ្ញមិនអាចយល់បាន, agnosticisme ) ដែលគេច្រើនពោលថា ជាលក្ខណៈនៃព្រះពុទ្ធសាសនា នៅមានគំនិតមួយទៀតមានអត្ថដ៏សុខុម-គម្ភីរភាព ដែលពួកអ្នកនិពន្ធខាងបច្ចិមប្រទេសមិនបានដឹង ឬបំភ្លេចចោលជាអសារបង់ ។ យើងមិនត្រូវភ្លេចទេ ថាព្រះពុទ្ធសាសនាកើតឡើងហើយ, ចំពេលវិវឌ្ឍនាការជាលំដាប់រស់នៅក្នុងរស្មីប្រាជ្ញានៃគម្ពីរឧបនិស័ទ (Upanishad) ដែលជាគម្ពីរប្រកបដោយអច្ឆរិយភាព ពណ៌នាអំពីចិន្តាខាងព្រហ្មញ្ញសាសនា បើកទ្វារវិបស្សនាបញ្ញាឲ្យភ្លឺស្វាងយល់ធម៌បាន ។ គម្ពីរនេះមានគុណសម្បត្តិជាអនេកប្បការ ដោយបានប្រមូលនូវសញ្ញាណដែលស្ថិតនៅពត់ពាយតាមគម្ពីរវេទ មកដំកល់ទុកជាវិធីប្រតិបត្តិ គឺយល់ថាមានអហេតុកធាតុ (Absolu) មានសភាពឧត្តមផុតហួសវិស័យនឹងដឹងបាន ហើយជាសច្ចធម៌មួយឯកឯង ។ ប្រជាកស្ត្រ

នីមួយៗ គោរពទេវតាតែរៀងៗ ខ្លួនដែលមានទេវល្អគុណៈប្រកបដោយគុណសម្បត្តិ និងបាបធម៌ដូចមនុស្សជាតិ (Anthropomorphiques) ដែលមានសភាពស្របគ្នានឹងគតិជាតិនៃនានាប្រទេស ៗ ដូចជាទេវតានៃប្រទេសឥណ្ឌា ឬអាទិទេពនៃប្រទេសអីស្រាអែល (Israël) អាទិទេពមានទេវចរិយាដូចជាតិជ្វីហ្វ (Juif) ដែលមានកិច្ចត្រង់ជួយការពារប្រជារាស្ត្រ, បំផ្លាញបច្ចាមិត្តហើយមានបាបធម៌ដូចមនុស្សសាមញ្ញ អាទិទេពមានចរិយាឫស្យាពេញចិត្តខាងការទទួលនូវសក្ការបូជា ឬពលិកម្ម. ខាងព្យាបាទនិងធ្វើទណ្ឌកម្មចំពោះអ្នកដែលមិនប្រតិបត្តិតាម ៗ តែចំពោះផែនការណ៍ខាងមនុស្សជាតិពីលើអាទិទេពទាំងនោះ មានអហេតុកធាតុប្រកបដោយវិមុត្តិសុខគ្មានលក្ខណ៍, ឯកភាព, គ្មានសភាពផ្សេងគ្នាដែលមានរូបបដិមាករប្រតិស្ឋានជាអាទិទេព ទុកសម្រាប់ឲ្យជនជាតិគោរព ; អាទិទេពបដិមាករនេះ គឺជារូបដែលកើតឡើងដោយសភាពឯកទេស ឬបាតុកភាពប្រកបដោយមនោសញ្ចេតនារចនាជាបុគ្គលាធិដ្ឋាន ៗ

ព្រះពុទ្ធសាសនាក៏បានប្រាប់ច្បាស់នូវអហេតុកធាតុនោះដែរ ៗ អហេតុកធាតុនេះ មានសំដែងទុកនៅក្នុងគម្ពីរព្រះវិនយបិដកខាងហីនយាន, តែព្រះសារីបុត្តជាមហាសាវកនៃព្រះសម្មាសម្ពុទ្ធលោកបានទេសនាចំពោះព្រះភិក្ខុសង្ឃថា: " ម្នាលអាវុសោទាំងឡាយ គេតែងឃើញមានសភាពមួយដែលគ្មានកើត, គ្មានចំរើន, គ្មានស្ថាបនា, គ្មានទម្រង់ ;

ម្នាលអាវុសោទាំងឡាយ បើគ្មានធាតុអ្វីដែលមានសភាពគ្មានកើត គ្មានចំរើន គ្មានស្ថាបនា គ្មានទម្រង់ទេ, ផ្លូវដែលចេញចាកសភាពកើត, ចម្រើន, ស្ថាបនា, ទម្រង់ ក៏គ្មានដែរ” ។

សញ្ញាណនៃអហេតុកធាតុនេះ បានចម្រើនជាកិយ្យោភាពឡើងជាលំដាប់ចំពោះការវិវត្តន៍ខាងព្រះពុទ្ធសាសនា រហូតដល់សុក្រិតភាពផ្នែកខាងពុទ្ធសាសនាមហាយាន ។ គឺចំពោះគណៈមហាយាន “យោគសា:” ដែលពាក្យអហេតុកធាតុទៅជាបញ្ហាមួយ ដែលនាំមកបុច្ឆាវិសជ្ជនាជាធម៌បរមត្ថ មានអត្ថដ៏សុខុមគម្ភីរភាព តាមន័យប្រកបដោយចិន្តាដ៏ខ្ពស់បំផុត មិនអាចមានលោកអ្នកប្រាជ្ញណា ពោលពីអហេតុកធាតុឲ្យមានអត្ថដ៏ជ្រាលជ្រៅជាងពួកគណៈនេះទៀតឡើយ ។

ចំណែកពួកបច្ចិមប្រទេសមិនបានជ្រាបច្បាស់នូវអត្ថដ៏សុខុមខាងធម៌បរមត្ថនៃព្រះពុទ្ធសាសនា ជ្រាបបានតែលក្ខណៈប្រកបដោយវិចារណញាណខាងព្រះត្រៃបិដកជាភាសាបាលី ដោយហេតុថាពួកនោះយល់បានតែសភាពកក់ស្ងួបស្ដើង ដែលពណ៌នាក្នុងគម្ពីរខាងលើនេះ ។ ការយល់ខុសបែបនេះមានចំពោះតែពួកបច្ចិមប្រទេស ដែលនិយមសិក្សាព្រះពុទ្ធសាសនាទៅតាមសម័យថ្មី ហើយបានយកគំនិតដែលគេអាចតាំងជាបញ្ហាបុច្ឆាវិសជ្ជនាទៅជាវិធានការ កំណត់ទុកថាជាសម្មាមតិតែមួយឯកឯង ។ ពួកខាងបូព៌ាប្រទេសតែងយល់នូវសភាវៈអ្វីៗ បានឆ្ងាយវែងទូលាយជាង

ពួកបច្ចិមប្រទេស ហើយមិនសូវមានយោបល់ចំទាស់ចំពោះសញ្ញាណនៃ
ពុទ្ធសាសនាខាងហីនយាន និងមហាយាន មិនដូចពួកខាងបច្ចិមប្រទេស
ច្រើនតែពោលទំនាស់ចំពោះបញ្ហាខាងសាសនា ។ ពួកខាងមហាយាន
យល់ថា គម្ពីរបាលីជាគម្ពីរប្រកបដោយសម្មាមតិដ៏វិសេស ហើយអនុម័តិ
បញ្ចូលគម្ពីរនេះទៅក្នុងគម្ពីរនៃលទ្ធិរបស់ខ្លួន; ពួកនេះគិតថាការពន្យល់នូវ
ព្រះបរមពុទ្ធោវាទថាគម្ពីរបាលីដែលមានសភាពតែមួយយ៉ាងគឺ អន្តេភាវៈ
(Exotèrique) ។ ព្រះសម្មាសម្ពុទ្ធទ្រង់មិនដែលទេសនាជាពាក្យទ្រិស្ត្រ
ទ្រង់ច្រើននិយមប្រើទ្រង់ប្រកបដោយមនោសញ្ចេតនា ព្រមទាំងបញ្ចូល
ឧទាហរណ៍ផ្សេងៗ តាមប្រពៃណីនៃប្រទេសឥណ្ឌា ។ តមក, មានធម៌
ខ្លះដែលព្រះអង្គទ្រង់មិនបានសំដែង, ហើយ បើតាមព្រះពុទ្ធដីកាថា
ជាធម៌មានសារៈ ប្រយោជន៍ ជាងធម៌ដែលព្រះអង្គទ្រង់ទេសនានោះទៅ
ទៀត ។ ជាតិនីមួយៗ បានយកវិជ្ជាដែលព្រះអង្គមិនបានសំដែងទៅរចនា
ដោយស្មានសព្វៗខ្លួន ហើយបានយកពុទ្ធោវាទទៅនិយមប្រើតាមប្រ-
ពៃណីអស់ហើយ បើតាមវិចារណញ្ញាណ មិនត្រូវបដិសេធនូវប្រពៃណី
នោះឡើយ ។ ពាក្យថា "ពុទ្ធសាសនា" នេះគ្រាន់តែជាពាក្យ
ប៉ុណ្ណោះ ។ បើតាមពិត, ពួកពុទ្ធសាសនិកជនមានជាច្រើន ហើយ
ក្នុងពុទ្ធសាសនិកជនម្នាក់ៗ តែងនិយមប្រតិបត្តិតាមព្រះពុទ្ធសាសនារបស់
ជាតិមានសភាពប្លែកៗគ្នា ។

(មានត)

# ពន្លឺអាស៊ីទ្វីប

## វគ្គទី ៦

La Lumière de l'Asie

*លោក ស៊ីរ-អេតវាំង អារណូលត៍ តែង*

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

តមក)

---

តមក, មានភគៈខាងកិត្តិគុណ គឺ អរូបរាគៈ ដែលមានលក្ខណៈជា អភិជនភាព ហើយមានលំអអាចបំភាន្តគំនិតពួកបណ្ឌិតបាន, ជាមាតានៃ កម្មិកភាពប្រកបដោយវិសារទៈ, ពេញចិត្តខាងសង្គ្រាម, ខាងការ ទៀយហត់ ៗ រួចទើប មានោ មកដល់ដែលមានសភាពក្រអឺតក្រទម ជាបិសាចខាងអំនួត; ហើយតមក មានសភាពដែលពេញចិត្តចំពោះខ្លួន ខាងក់ចាបញ្ញោតគឺឧទ្ធច្ចៈ មានពួកពាលរូបអាក្រក់ពន់ពេកៈបាមរោមជា បរិក់ខ្លះ លូនខ្លះ ហើរដូចជាសត្វតីង្គក់ខ្លះប្រចេវខ្លះ ៗ ក្រៅពីនោះ, មានសេចក្តីល្ងង់ជាមេខាងខ្វាចចំពោះអយុត្តិធម៌ គឺ អវិជ្ជា(១) ជាមេអាប គួរឲ្យខ្ពើមរអើមពន់ពេក ៗ អវិជ្ជាមកដល់ធ្វើឲ្យកាន់តែងងឹតខ្មាំង ចំណែកខាងគិរីទាំងប៉ុន្មានរំជួលដល់បាតក្រោម ព្រះសង្ឃរាបកបោក

---

១ អវិជ្ជាមានន័យថា ល្ងង់លុះក័ន្តប្រាជ្ញ ។ "អវិជ្ជា" បើតាមអ្នកប្រាជ្ញខាងលោកកូឡិបុក (Colebrook) ជាតិសភាពប្រមាទដែលយល់ថា វត្ថុមិនស្ថិតថេរ ជាស្ថិតថេរទៅវិញ ។

ស្រែកសីហនាទជាខ្លាំង, ពពកក្លាយភ្លៀងធ្លាក់មកយ៉ាងធំអស្ចារ្យ; តាំង ធ្លាក់ចុះពីនភាល័យ, ព្រះធរណីញ័រកម្រើកសព្ទកន្ទ្រឹងដូចជាគេយកភ្លើងទៅដុតដំបៅធំរបស់វាដូច្នោះ; នៅលើអាកាសងងឹត មានផ្លេកបន្ទោរភ្លឺផ្លាលព្រាលពាសពេញ ហើយមានសូរសព្ទស្ទាបហើរព្រួសូរសៀងបែបហួច, ពាក្យពោលគឹកកងរំពង, សម្រែកលូចេញពីមុខពាលទុច្ចរិតចក្រ ក្រឡោតក្រឡេកមើលមកមានថ្ងាសធំសម្បើមអស្ចារ្យគួរឲ្យខ្លាច ហើយមានពួកយមរាជ ទ្រង់ទ្រាយមាំក្រអាញនៅស្ថាននរកចាកចេញពីព្រះរាជនិវេសនដ្ឋានផ្សេងៗ បាននាំកងពលយោធាជាច្រើនមកតស៊ូនឹងព្រះបរមពោធិសត្វ ។ តែព្រះបរមពោធិសត្វទ្រង់ឥតមានព្រះទ័យញាប់ញ័រសោះឡើយ ទ្រង់គង់ជាស្ងប់ដោយមានទសបារមីធម៌ជាអាវុធ ប្រៀបដូចជាទីក្រុងធំ ដែលមានក្លោងទ្វារនឹងកំពែងការពារយ៉ាងមាំមួនដូច្នោះ; ហើយរុក្ខជាតិពិសិដ្ឋ (L'arbre Sacré) គឺព្រះពោធិព្រឹក្សនៅកណ្ដាលព្យុះសង្ឃរានោះ ក៏ឥតមានកម្រើកសោះឡើយ, ហើយមានសន្ធឹ-ភ្លឺស្វាងរុងរឿង ស្ថិតនៅស្ងៀមស្ងាត់ ដូចជាពេលដែលព្រះចន្ទខាងសុក្កបក្ខក្នុងសា-យណ្ហសម័យ គ្មានព្រះពាយធ្វើឲ្យជ្រុះពីអជ្ឈាកាសនូវទឹកសន្សើម មានសភាពភ្លឺចាំងថែងដូចជាខ្សែមុក្តា; ហើយពាក្យសូរស័ព្ទព្រួលាន់រំពងនោះព្រួកាន់តែឆ្ងាយទៅខាងក្រោមម្លប់សាខានៃអជ្ជបាលនិគ្រោធ ។

ដល់យាមទីបី, ព្រះធរណីក៏ស្ងប់ស្ងៀម, ពួកសេនាមារក៏ហោះហើរទៅលើអាកាសបាត់ ហើយព្រះពាយបក់រំភើយៗក្រោមព្រះចន្ទដែល

មានពពកបាំងបាត់ ៗ ក្នុងពេលនោះ ព្រះបរមពោធិសត្វក៏បានត្រាស់ជាព្រះ**ស**ម្មាសម្ពុទ្ធ; ព្រះអង្គបានជ្រាបច្បាស់នូវជីវភាពដែលស្ថិតនៅក្នុងភ**ព**ទាំងអស់ ព្រមទាំងហេតុប្បច្ច័យ ហើយជីវភាពនៃសត្វលោកនេះ មានចំនួនប្រាំរយហាសិប ដោយព្រះប្រាជ្ញាដែលមានសភាពភ្លឺស្វាងចាំងថែងពីលើ**ជា**តិ**ស**ត្វលោក ដែលស្ថិតនៅក្នុងអនិច្ចតាធម៌ ៗ ប្រៀបដូចអ្នកដំណើរម្នាក់ដែលបានទៅដល់កំពូលភ្នំមួយ ហើយក្រឡេកមើលមកខាងផ្លូវដើរ មានសភាពវៀចកោងបត់បែន ដែលខ្លួនទើបនឹងដើរមកអម្បាញ់-មិញនេះ ឃើញគុហាជ្រលងភ្នំ, គុម្ពោតព្រៃដែលមើលពីចម្ងាយដូចជាវត្ថុខ្មៅមួយដុំ, ចុកបឹងមានទឹកភ្លឺពណ៌ខៀវបែបចង់បំភ័ន្តគំនិតអ្នកមើល ហើយនឹងជង្ហុកជាច្រើនដែលបានឆ្លងរួចមកហើយ, ហត់នឿយជិតផុតខ្យល់អស្សាសៈ បស្សាសៈ, កំពូលភ្នំខ្ពស់គួរឲ្យស្ញើបពន់ពេក ដែលខ្លួនព្យាយាមឡើងមកមានច្រាំងរអិលជិតធ្លាក់, ខាងក្រោមឃើញវាលមានព្រះសុរិយាចាំងថែងស្ទើក្ដី, ព្រោះ, រអាងនឹងបឹង, ហើយឆ្ងាយដាច់កន្ទុយភ្នែក, មានវាលដែលខំត្រាច់ដើរកាត់ពីបឋមមកទាល់តែមកដល់កំពូលគិរី ដែលមានពពកខៀវផ្ទៃមេឃអណ្តែតពីលើនភាល័យនេះជា-បរិយោសាន ៗ ឯព្រះសម្មាសម្ពុទ្ធដែលព្រះអង្គបានត្រាស់ហើយ ទ្រង់ក៏ពិចារណានូវវដ្ដសង្សារគឺខ្សែជីវភាពដែលត ៗ គ្នាពីមុនមក តាំងពីកាលទំនាបដែលជីវភាពមានលក្ខណៈជានិមិត្តកៈ រហូតមកដល់ទីស្ថានកាន់តែ

ខ្ពស់ៗ ឡើង ដែលបារមីធម៌ទាំងដប់នេះចាំអ្នកដំណើរដើម្បីនឹងទទួលធ្វើជាមគ្គុទ្ទេសក៍ នាំទៅកាន់មហាមេឃជាអវសាន ។ ព្រះសម្ពុទ្ធបានប្រាប់ច្បាស់ថា ជីវភាពថ្មីត្រូវប្រែកាត់នូវជីវភាពអតីតដែលសាបព្រោះ, ថា ក្រោយដែលបានឈប់សម្រាកមួយស្របក់ ជីវភាពនោះក៏ត្រាច់តទៅទៀត, រក្សាទុកនូវផលបុណ្យដែលបានធ្វើរួចមកហើយយកទៅផ្ទេរផ្ទួនឹងបាបពីអតីត:: ថា យ៉ាងដូចម្ដេចក្នុងជីវភាពនៃសត្វនិមួយៗ បុណ្យដែលធ្វើឲ្យចំរើនខាងបុណ្យ, បាបដែលធ្វើនាំឲ្យកើតបាបជាថ្មី; ព្រោះមរណភាពគ្រាន់តែបញ្ឈប់គណនីនៃប្រាក់ចំណាយ (បាប) និងប្រាក់ចំណូល (បុណ្យ) ហើយតាមវិធីលេខនព្វន្តត្រឹមត្រូវជាអស្ចារ្យ, បានបូករួមហើយលើកនូវបុណ្យនិងបាបដែលបោះពុម្ពភ្ជាប់ពិត ប្រាត្យក្សគត មានភ័ន្តប្រឡំយកទៅបញ្ចូលនឹងជីវភាពថ្មី ដែលធ្វើដំណើរជាបឋមតៗទៅទៀត. ហើយដែលប្រមូលរួបរួមហើយចុះគណនីអំពីចិន្តានឹងកម្មភាពអតីត, សង្គ្រាមព្រមទាំងជោគជ័យ, និស្ស័យ, និងវាសនាពីអតីតជាតិ ៗ

ហើយក្នុងពេលអធ្រាត្រ, ព្រះទ័យនៃព្រះបរមពោធិសត្វ បានឡើងដល់អភិញ្ញា ដែលជាញាណភ្លឺស្វាងរុងរឿងជាអស្ចារ្យ អាចប្រាប់ច្បាស់នូវធម៌ទាំងអស់, ភព, លោកនេះនិងលោកកុត្តរភព, ហ្វូងតារាផ្សេងៗ, ព្រះសុរិយានិងលោកធាតុជាច្រើនមិនអាចនឹងគណនាបាន ដែលវិលទៅតាមវិធីត្រឹមត្រូវឥតមានខ្ចោះ ប្រកបដោយអច្ឆរិយភាពទៅ

តាមក្រមរូបរួមគ្នា តែមានលក្ខណៈផ្សេងពីគ្នា ហើយមានសមាសភាព មូលបួលតែមួយឯកឯង ពិតមែនតែដោយឡែកៗពីគ្នា ៗ លោកធាតុទាំងនេះជាកោះប្រាក់នៃមហាសាគរ មានពណ៌ខៀវផ្ទៃមេឃ, គ្មានត្រើយ, គេមិនអាចយល់បាន ដែលមានទឹកមិនចេះស្រកស្រុត ហើយមានរលកបោកបក់ចូលទៅក្នុងទឹកជោរនោចនៃអនិច្ចតាធម៌ជានិរន្តរកាល ៗ ព្រះអនាវរណញ្ញាណបានទតយល់ច្បាស់ នូវព្រះអាកាសដែលមានព្រះ-ពជគមនាគមន៍ ប្រកបដោយអទស្សនីយភាពដ៏សុខុមចំពោះបរិវារជាច្រើន ដែលវិលជុំវិញខ្លួនឯង ព្រមទាំងចក្រវាឡមានវិទ្ធានុភាព ដែលនៅក្រោមព្រះបញ្ញានៃហ្វូងតារាឯទៀត បានជាតារាមួយផ្សេរទៅតារាមួយទៀតនូវរស្មីជីវភាពដែលកើតពីទីកណ្ដាល វិលទៅកាន់រណ្ឌមណ្ឌលប្រ-កបដោយអនន្តមាត្រ (infini) នេះហើយដែលញាណព្រះសម្មាសម្ពុទ្ធ បានឃើញជាក់ច្បាស់ដោយព្រះប្រាជ្ញាចក្ខុ ព្រមទាំងមណ្ឌលធំតូចនៃចក្រវាឡទាំងឡាយ និងគណនីនៃកល្ប[1] និងមហាកល្ប ដែលជាកាលវិធី (mesure du temps) ឥតមានអ្នកណាកំណត់ ឬអាចយល់បាន ដែលគេហៅថាកាលសម្រាប់លោកដែលចំរើន វិនាស (បើប្រសិនជាអ្នកណាមួយអាចរាប់ដំណក់ទឹកក្នុងស្ទឹងគង្គា ពីប្រភពរហូតដល់សមុទ្រ

---

១ កល្ប គឺមួយថ្ងៃក្នុងស្ថានព្រហ្មត្រូវជា ៤-៣២០ លានឆ្នាំមនុស្សដល់ចុងកល្បនីមួយៗ លោកនេះត្រូវលាយចូលទៅនឹងអាទិទេវធម៌ (divinité) ។

បាន ) ដែលមានសត្វលោកនៅក្នុងមហាមេឃបានបំពេញករណីយកិច្ច ដ៏ប្រសើរឡើងចុះអាប់អោនហេតុដល់មរណភាពជាអវសាន, ពីសតវត្សមួយទៅសតវត្សមួយ ៗ ព្រះបរមគ្រូជាម្ចាស់ក៏បានទតយល់នូវដំណើរដ៏កំពូលចំពោះអនន្តមាត្រ ដែលមានពណ៌ខៀវផ្ទៃមេឃ ហើយបានពិនិត្យគ្រប់បែបយ៉ាង គ្រប់លោកធាតុទាំងមូល នឹងអនន្តចក្រវាឡ ព្រមទាំងចលនានៃចក្រវាឡនីមួយៗ ដែលមានចំហាយផ្សាយក្តៅចេញ; ច្បាប់មានសភាពមិនប្រែប្រួល ព្យាយាមប្រតិបត្តិដោយស្ងប់ស្ងាត់ ដែលមានធនូៈបង្ខំឲ្យស្រមោលវិវត្តន៍ទៅកាន់ពន្លឺ, មរណៈទៅកាន់ជីវៈ បំពេញធម្មជាតិដែលមានប្រហោង, ប្រឡោះ (អាកាស), រចនាឲ្យមានទម្រង់, ធាតុណាដែលគ្មាន, ប្រែសភាពល្អទៅកាន់សោភ័ណ, ពីសោភ័ណទៅកាន់សុក្រិត, ដោយមានបង្គាប់ប្រកបដោយសន្តិ, ដែលគ្មានបុគ្គលណាចាត់ចែងរៀបចំ តែគ្មានបុគ្គលណាអាចជំទាស់នឹងសេចក្តីបង្គាប់នោះបាន, ព្រោះច្បាប់នោះស្ថិតនៅខ្ពស់លើពួកសត្វបុគ្គល ឬ ព្រះឯណា-ស្រពទៅទៀត ច្បាប់នោះ ជានិច្ចភាព (immuable) អចិន្តេយ្យភាព (ineffable) ព្រមទាំងឧត្តមភាព គឺជាអំណាចអស្ចារ្យមួយដែលប្រតិស្ឋានកើតឡើង, ធ្វើឲ្យវិនាស, បង្កើតជាថ្មីឡើងទៀត, គ្រប់ត្រាធម្មជាតិទាំងអស់តាមវិធានការខាងគុណធម៌ដែលប្រមូលមកឲ្យនាមថាល្អ ពិតហើយមានប្រយោជន៍ ដោយយល់ថា អ្នកណាចូលទៅបម្រើអំណាចនោះ

ដោយចិត្តស្មោះស្ម័គ្រ គេទុកជាល្អ, វត្ថុអ្វីដែលជំទាស់ក្នុងការបម្រើនេះ គេទុកជាអាក្រក់: ព្រោះហេតុដូចនេះ ជនណាដែលប្រតិបត្តិការទៅតាមធម្មជាតិរបស់ខ្លួន ប្រព្រឹត្តល្អ, បក្សាស្ទាំងដែលនាំយកអំពាវដែលប្រឡាក់ដោយលោហិតទៅឲ្យកូនបរិភោគ ប្រព្រឹត្តល្អ, ដំណក់ទឹកសន្សើមនឹងគាកដែលមានរស្មី ចាំងភ្លឺដូចគ្នាហើយធ្វើសហការជួយឧត្តមកិច្ចនៃលោកធាតុ ហើយមនុស្សជាតិដែលរស់នៅហើយ ធ្វើមរណភាពទៅវិញ, ស្លាប់ព្រោះឧត្តមហេតុ, បើមនុស្សទាំងនោះបម្រើប្រព្រឹត្តទៅតាមសីលធម៌ហើយនឹងធនូ: ដ៏មាំមួនមិនត្រឹមតែជួយឧបត្ថម្ភគ្នាទៅវិញទៅមក ថែមទាំងមិនប្រព្រឹត្តអករណីយកិច្ចត្រង់ការឃាត់ហាមមិនឲ្យសត្វលោកតូចធំដែលរងទុក្ខក្នុងវដ្តសង្សារ មិនឲ្យវិវត្តទៅនៅទៅបាន ។

តែដល់មកយាមទីបួន ព្រះសម្មាសម្ពុទ្ធបានជ្រាបច្បាស់នូវហេតុដែលនាំឲ្យកើតទុក្ខ, ទុក្ខដែលរួបរួមនឹងបាបអកុសលកាំងកមិនឲ្យប្រាបប្រព្រឹត្តទៅតាមធម៌ ប្រៀបដូចជាផ្សែងនឹងអាចម៍ដែកសន្ធប់ភ្លើងដែលនាយសុវណ្ណការបានដុត ។ ព្រះអង្គទ្រង់ទតឃើញនូវទុក្ខសច្ច ដែលជាអរិយសច្ចទី ១ ហើយយល់ថាទុក្ខជាស្រមោលនៃជីវភាព ជាធម៌មានហេតុមានបច្ច័យទាក់ទងគ្នានឹងជីវភាពនេះ ហើយគេអាចបោះបង់ចោលនូវទុក្ខនេះបាន លុះត្រាតែផុតរលត់ជីវិត ព្រមទាំងរលាយនូវសភាពផ្សេងៗរបស់ជីវភាព គឺ: បដិសន្ធិ វុឌ្ឍិធម៌ ជរា ស្នេហា បដិឃៈ កាមច្ឆន្ទ: ទុក្ខ សត្វ និងកម្មិកភាព ។ (មានត)

# ពុទ្ធសាសនានៅប្រទេសជប៉ុន

## ក្នុងសម័យអតីតនិងសម័យបច្ចុប្បន្ន

## ឃុនបណ្ណាទរក្ស ប៊ី-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ

ស្រង់ចាកច្បាប់ធម្មចក្ក ភាសាថៃ របស់ក្រសួងពុទ្ធសាសនបណ្ឌិត្យភ្នំពេញ

លេខ ថ. ៤២៣ / ១ ទំព័រ ៨៣១ - ៨៣៧

គ្រប់ ៗ ប្រទេសក្នុងលោក ទោះសម័យណាក៏ដោយ សុទ្ធតែមានសាសនាជាគ្រឿងចង្អុលផ្លូវ ឲ្យប្រទេសមានដំណើរឈានលឿនទៅមុខជាធម្មតា ពពួកជនរបស់ប្រទេស ខ្វះការរាប់អានកាន់សាសនាមិនបានឡើយ ។ បើប្រទេសណាគ្មានសាសនាហើយ ប្រទេសនោះក៏គ្មានសេចក្ដីសុខសប្បាយនិងគ្មានអារ្យធម៌ ។ សាសនាមិនមែនគ្រាន់តែជាគ្រឿងជម្រះសេចក្ដីអាក្រក់របស់មនុស្សប៉ុណ្ណោះទេ អាចជាគ្រឿងដឹកនាំអារ្យធម៌ឲ្យចូលមកក្នុងប្រទេសនិងប្រជាជនទៀតផង សាសនាចាត់ថាជាគោលសំខាន់មួយយ៉ាងក្នុងផ្លូវជាទីកើតអារ្យធម៌ ។ គ្រប់សាសនាដែលកើតឡើងក្នុងប្រទេសខ្លួនក្ដី ផ្សាយពីប្រទេសដទៃចូលមកក្ដី សុទ្ធតែមានពន្លឺរស្មីនៃអារ្យធម៌និងវឌ្ឍនធម៌ជាប់តាមបំភ្លឺមកផងជាដរាប ខុសគ្នាតែចំនួនច្រើនឬតិចប៉ុណ្ណោះ ។

ក្នុងប្រទេសជប៉ុន អ្នកប្រាជ្ញទាំងឡាយនាំគ្នាសន្និដ្ឋានថាសាសនាជាគ្រឿងចង្អុលប្រាប់អារ្យធម៌យ៉ាងល្អ បើនឹងនិយាយថាជាតិជប៉ុនបានចំរើនរុងរឿងឡើងព្រោះតែសាសនាក៏មិនខុស រាប់តាំងពីសម័យព្រេង

នាយហេតុមកដល់សព្វថ្ងៃនេះក៏ដូចគ្នា សាសនាជាករណីយកិច្ចរបស់ជាតិយ៉ាងសំខាន់បំផុត ។ ពោលចំពោះសាសនាដែលសំខាន់បំផុតរបស់ជាតិជប៉ុន មាន ២ យ៉ាងគឺ សាសនាជិនតោ ១ សាសនាពុទ្ធ: ១ ។ សាសនាទាំង ២ នេះ មានប្រាកដនៅក្នុងប្រទេសជប៉ុនជាយូរអង្វែងមកហើយ ប្រជាជនក៏មានសេចក្ដីនិយមរាប់អានសាសនាទាំង ២ នេះដោយច្រើន ។ មានសាសនា ២ ទៀត គឺលទ្ធិខុងជឺ ១ សាសនាគ្រិស្ដ ១ ទាំង ២ នេះមិនមែនជារបស់សំខាន់នៃជាតិជប៉ុនទេ ប្រជាជនក៏មិនសូវនិយមរាប់អានឡើយ ។ បណ្ដាជនជប៉ុនមានសេចក្ដីនិយមរាប់អានក្នុងលទ្ធិសាសនាផ្សេងៗគ្នា, អ្នកណាមានសេចក្ដីជឿក្នុងសាសនាណា ក៏បែរទៅកាន់ផ្លូវសាសនានោះទៅតាមគំនិតរៀងខ្លួន ។ ព្រោះតែការយល់ឃើញខុសគ្នាដូច្នេះហើយ បានជាបណ្ដាលឲ្យកើតទាស់ទែងគ្នាខ្លះក៏មាន ។ សាសនាជិនតោនិងសាសនាពុទ្ធ: មានសេចក្ដីចំរើនប្រហែលគ្នា ជាគូប្រណាំងប្រជែងគ្នាអស់វេលាយូរមកហើយទាំងកើតមកជាប់គ្នា ។ ដូច្នេះ ខ្ញុំនឹងនាំមកពោលរម្លេគក្នុងទីនេះតែម្ដង ដើម្បីឲ្យឃើញថា សាសនាទាំងពីរនេះជាប់ទាក់ទងគ្នាដូចម្ដេច ។

ដើមដំបូង ប្រជាជនជប៉ុននាំគ្នានិយមរាប់អានកាន់សាសនាជិនតោជាចំនួនច្រើន, វេលាខាងក្រោយសាសនាពុទ្ធ:បានចំរើនផ្សាយចូលទៅក្នុងប្រទេសជប៉ុន ប្រជាជនក៏នាំគ្នាបែរមកនិយមរាប់អានកាន់សាសនាពុទ្ធ: រឹតតែច្រើនៗឡើងតាមលំដាប់ ទាល់តែជាហេតុឲ្យសាសនាជិនតោ

ហោយទៀតសាបសូន្យទៅ ។ តាមពិត សាសនាជិនតោជាសាសនាដើមកំណើតរបស់ជាតិជប៉ុន ទាំងកើតឡើងក្នុងប្រទេសជប៉ុនតែម្ដង ជាសាសនាចាស់របស់ជាតិជប៉ុនមុនសាសនាណា ៗ ទាំងអស់ តែមិនប្រាកដថាកើតឡើងក្នុងជាន់ណាវេលាណាទេ ។ ជិនតោបានប្រៀនប្រដៅថា "មនុស្សយើងកាលស្លាប់ទៅហើយ ក៏ដូចជាការផ្លាស់រូបកង ឬ ផ្លាស់គ្រឿងសម្លៀកបំពាក់ប៉ុណ្ណោះ វិញ្ញាណមិនមែនសាបសូន្យបាត់ទៅទេ គង់នៅចាំថែរក្សាគ្រួសារជាប់ជានិច្ច ព្រោះវិញ្ញាណជារបស់មិនចេះសាបសូន្យ", ខនេះឯងជាករណីយ៍ដ៏សំខាន់ឲ្យជាតិជប៉ុនមានសេចក្ដីក្លាហាន ។ ក្រៅពីនេះ ជិនតោមានប្រៀនប្រដៅឲ្យគោរពបុព្វបុរសរបស់គេទៀត គោលដោយត្រង់ គឺព្រះរាជាម្ចាស់ផែនដីរបស់គេនោះឯង ។ តាមគតិរបស់សាសនានេះប្រកាន់ថា កោះជប៉ុននៅសព្វថ្ងៃ គឺជាចំណែកមួយរបស់ដួងព្រះអាទិត្យ ដែលបែកខ្ទេចមកហើយក៏ក្លាយទៅជាកោះឡើង ខាងក្រោយបានប្រទានព្រះរាជានឹងព្រះរាជិនីឲ្យមកនៅក្នុងកោះជប៉ុន តមកទៀត ព្រះរាជានឹងព្រះរាជិនីជាអ្នកឲ្យកំណើតដល់ប្រជាជនជប៉ុន ។ បើនិយាយដោយត្រង់គឺគេប្រកាន់ថា ព្រះរាជាតសែស្រឡាយមកអំពីព្រះអាទិត្យ, ឯប្រជាជនតសែស្រឡាយមកអំពីព្រះរាជា, ព្រះរាជាក៏គឺជាបុព្វបុរសដ៏ខ្ពង់ខ្ពស់បំផុតរបស់គេនោះឯង ។ កាលគេស្រឡាញ់ទឹងគោរពបុព្វបុរសរបស់គេៗ ក៏ត្រូវតែក្លាហានហ៊ានផ្ដាញ់សត្រូវគ្រប់យ៉ាង ដើម្បី

ទឹងបូជាគុណបុព្វបុរសរបស់គេ; ផលល្អអាក្រក់ដូចម្ដេចកាលបើកើតមានឡើងដល់បុព្វបុរសរបស់គេ ក៏ដូចជាកើតមានឡើងដល់ខ្លួនគេដែរ ។ អាស្រ័យហេតុនេះ ជនជាតិជប៉ុនទើបជាអ្នកមានសមគ្គសាមគ្គីនឹងគ្នាល្អជាទីបំផុត ព្រោះគេយល់ឃើញថាខ្លួនគេជាប់សែស្រឡាយមកជាមួយគ្នា, ចាត់ថាសាសនាជិនតោនេះជាគ្រឿងបង្អួលផ្លូវនៃអារ្យធម៌ឲ្យដល់ជាតិជប៉ុនជាយ៉ាងល្អ ។ អ្នកស្រុកជប៉ុនមានសេចក្ដីក្លាហាន ស្រឡាញ់ជាតិស្រឡាញ់ព្រះមហាក្សត្រ ក៏ព្រោះតែគតិខាងផ្លូវសាសនាជិនតោនៅចាំអប់រំលើកតំកើងបង្កើនឲ្យលឿនទៅមុខ ដូច្នេះបានជាសាសនាជិនតោតាំងនៅក្នុងសេចក្ដីនិយមរាប់អានរបស់ជនជាតិជប៉ុនជាចំនួនច្រើន ៗ ខាងពុទ្ធសាសនាវិញ ជាតិជប៉ុនបានប្រកាន់ថាជាសាសនាដ៏សំខាន់របស់គេដូចគ្នា ប៉ុន្តែជាសាសនាដែលមានគតិប្លែសេចក្ដីយល់ឃើញជាបដិប័ក្សនឹងសាសនាជិនតោជាច្រើន សូម្បីដូច្នោះពុទ្ធសាសនាក៏នៅតែបំរើនរុងរឿងក្រៃលែងជាងសាសនាជិនតោ ៗ ប្រជាជនដែលមានសេចក្ដីស្រឡាញ់រាប់អានកាន់សាសនាជិនតោ មានប្រមាណត្រឹម ១៦ លាននាក់ប៉ុណ្ណោះ ចំណែកដែលកាន់សាសនាពុទ្ធៈមានដល់ ៤៨ លាន ៥ សែននាក់ ច្រើនជាងសាសនាជិនតោ ៣២ លាន ៥ សែន ៗ អ្នកប្រាជ្ញទាំងឡាយនាំគ្នាសន្និដ្ឋានថា សាសនាពុទ្ធៈបានបង្អួលផ្លូវដំណើរចូលទៅកាន់សេចក្ដីរុងរឿងឲ្យដល់ជាតិជប៉ុនមិនមែនតិចទេ ដូចក្នុងកាល ព.ស. ១០៩៥ ចាត់

ជាគ្រាដំបូងដែលសាសនាពុទ្ធបានផ្សាយទៅដល់ប្រទេសជប៉ុន ដោយមានព្រះរាជាម្ចាស់ផែនដីនៃប្រទេសកោរ៉េបានផ្ញើព្រះពុទ្ធរូបទៅថ្វាយព្រះបាទកិម្មេអ៊ិជាម្ចាស់ផែនដីជប៉ុន ។ តពីនោះមកមិនយូរប៉ុន្មាន ព្រះរាជាបានបញ្ជូនព្រះសង្ឃចូលទៅផ្សាយព្រះពុទ្ធសាសនាទៀត ។ ព្រះសង្ឃដែលទ្រង់បញ្ជូនទៅនេះឯងបាននាំយកវិជ្ជាសេដ្ឋវិទ្យាសិល្បកម្ម វិស្វកម្មចូលទៅផ្សាយឲ្យដល់អ្នកស្រុកជប៉ុនជាយ៉ាងល្អ រហូតដល់ការដាំដំណាំក៏ដូចគ្នា, ចាត់ថាពុទ្ធសាសនាបានដឹកនាំឲ្យជាតិជប៉ុន ភ្លឺច្បាស់ក្នុងវិទ្យាការនោះមិនមែនតិច ចាត់ថាជាវិធីនៃអារ្យធម៌ដ៏សំខាន់មួយចំណែក ។

ប៉ុន្តែក្នុងជាន់ដំបូង ដែលព្រះពុទ្ធសាសនានឹងមានសភាពត្រដាក់ត្រដំផ្សាយបរិបូណ៌ក្នុងប្រទេសនេះបានល្អ ពុទ្ធសាសនិកជនត្រូវធ្វើការធ្ងន់ៗអស់វេលាជាច្រើនឆ្នាំ ត្រូវធ្វើការកាប់សម្លាប់គ្នាក្នុងរវាងបរិស័ទរបស់សាសនាជិនតោទាល់តែបេញខ្ទះឈាម ។ សង្គ្រាមរបស់សាសនាទាំង ២ នេះបានផ្ដាញ់គ្នាអស់វេលាជាយូរអង្វែង ក្នុងទីបំផុតសាសនាដែលមានរសធម៌ដ៏ត្រដាក់ត្រដំក្នុងផ្លូវបកតិសុខ ប្រាសចាកការបៀតបៀនគ្នានឹងគ្នាទាំងសម្បូណ៌ទៅដោយសិល្បវិទ្យាការដ៏មានឧដាររស គឺព្រះពុទ្ធសាសនាបានតាំងទុកនៅសេចក្ដីមានជ័យ អាចគ្របសង្កត់ទឹកចិត្តជាតិជប៉ុនពេញទាំងប្រទេស ។ ពុទ្ធសាសនាមានអ្នកនិយមរាប់អានផ្សាយទៅក្នុងប្រទេសជប៉ុនត្រឹមណា រស្មីរបស់ជិនតោក៏ចេះតែរោយរៀវថយចុះទៅត្រឹមណោះ

ធ្វើឲ្យបរិស័ទរបស់ជិនតោក្តៅក្រហាយមិនតិច, ក្រោតមកជិនតោក៏ឈាន ទៅកាន់សេចក្តីសាបសូន្យតាមលំដាប់ ។

លុះមកដល់រជ្ជសម័យរបស់ព្រះនាង ស៊ុយកោ ម្ចាស់ផែនដីជប៉ុន ក្នុង ព. ស. ១១៣៦ ដល់ ១១៧១ បានកើតការផ្លាស់ប្តូរសាសនាមួយគ្រា ដោយប្រកាន់យកសេចក្តីពេញចិត្តរបស់មហាជនជាធំ ។ ដូច្នេះឯង សាសនាពុទ្ធ: ដែលនៅក្នុងសេចក្តីនិយមរបស់មហាជន ទើបបានត្រូវលើកឡើងជាសាសនាផ្លូវរាជការរបស់ជប៉ុន ជាសាសនារបស់ជាតិជំនួសសាសនាជិនតោដែលជាសាសនាដើមរបស់ជប៉ុន ។ ក្នុងវេលានេះមានក្សត្រជប៉ុនជាច្រើនបានចេញបួសក្នុងព្រះពុទ្ធសាសនា ហើយយកព្រះទ័យទុកដាក់ទំនុកបម្រុងព្រះពុទ្ធសាសនាជាយ៉ាងល្អ; សេចក្តីចំរើនលូតលាស់របស់ពុទ្ធសាសនាបានដំណើរទៅយ៉ាងរៀបរយតៗមក ។

លុះមកដល់រជ្ជសម័យរបស់ព្រះបាទមស្សុហិតោ ក្នុងរវាង ព. ស. ២៤១០ ដល់ ២៤៥៥ នោះ ព្រះអង្គមានព្រះរាជប្រាថ្នានឹងរៀបចំប្រទេសរបស់ព្រះអង្គឲ្យសមនឹងពាក្យថា "ជប៉ុន" គឺត្រូវការឲ្យគេប់ៗយ៉ាងក្នុងប្រទេសជប៉ុនជារបស់ជាតិជប៉ុនដោយត្រង់ រួមទាំងការសាសនាផង ដូច្នោះទើបបានកើតការផ្លាស់ប្តូរឡើងមួយគ្រាទៀត ដោយលើកយកសាសនាជិនតោ ដែលជាសាសនាដើមរបស់ជប៉ុន ទាំងកើតឡើងក្នុងប្រទេសជប៉ុន ជាសាសនាផ្លូវរាជការតមក ។ សូម្បីដូច្នោះ

សាសនាពុទ្ធៈក៏គង់តែនៅក្នុងសេចក្តីនិយមរាប់អានរបស់ប្រជាជនជប៉ុនជាចំនួនច្រើនជាងសាសនាជិនតោ ជាង ២ ភាគ បាត់ជាសាសនាពុទ្ធៈបានជាចំណែកមួយ ដែលអប់រំធម្មចរិយាដ៏ពិតប្រាកដឲ្យដល់ជាតិជប៉ុន នាំជប៉ុនចូលកាន់វិថីនៃអារ្យធម៌ដ៏ល្អ សមគួរដែលអ្នកស្រុកជប៉ុននឹងត្រូវនឹករឭកដល់ជានិច្ច ។ ក្នុងឥឡូវនេះ ព្រះពុទ្ធសាសនាក៏ជាសាសនាដែលសំខាន់របស់ជាតិជប៉ុន ប្រាកដថាវេលានេះវត្តពុទ្ធសាសនាក្នុងប្រទេសជប៉ុន មានចំនួនដល់ ៧០,០០០ វត្ត (៧ ម៉ឺន វត្ត) សំដែងឲ្យឃើញថាពុទ្ធសាសនាក្នុងប្រទេសជប៉ុនចំរើនរុងរឿងមិនមែនតិចទេ ។

ក្រៅពីសាសនាជិនតោនិងសាសនាពុទ្ធៈ នៅមានលទ្ធិខុងជួដែលបានផ្សាយទៅដល់ប្រទេសជប៉ុនដែរ ។ តាមពិត លទ្ធិនេះបានផ្សាយទៅដល់ប្រទេសជប៉ុនមុនសាសនាពុទ្ធៈ ប្រាកដថាបានផ្សាយចូលទៅដល់ក្នុងរាវ៉ាង ព. ស. ៨២៨ ។ លទ្ធិនេះមានដើមកំណើតកើតនៅក្នុងប្រទេសចិនជាមុន ខាងក្រោយទើបបានផ្សាយទៅដល់ប្រទេសជប៉ុន ប៉ុន្តែមានបណ្តាជនទទួលរាប់អានតិចគ្នា សូម្បីពាក្យប្រដៅរបស់សាសនានេះមិនទំនាស់នឹងសាសនាជិនតោក៏មែនហើយ ប៉ុន្តែអ្នកផ្សាយសាសនាមិនសូវខំប្រឹងប្រែង ឬក៏ខ្វះខាតគតិរបស់សាសនា ទើបមិនអាចនឹងទាញទឹកចិត្តរបស់ប្រជាជនឲ្យបែរមកនិយមរាប់អាន់បាន ។ ក្នុងសម័យនេះលទ្ធិខុងជួហាក់ដូចជាសាបសូន្យអស់ទៅហើយ មិនប្រាកដថាមានមនុស្ស

កប់អានច្រើនឬតិច ៗ ខាងផ្លូវរាជការ ជប៉ុនក៏មិនបានប្រកាន់សាសនាខុងជូថាជាសាសនាសំខាន់របស់ជាតិទេ; សាសនាខុងជូក៏ចេះតែរោយរៀវសាបសូន្យទៅរាល់ថ្ងៃដូចជាបាត់រស់ទៅហើយ ៗ

មានសាសនាមួយទៀតគឺ សាសនាគ្រិស្ត ៗ បានផ្សាយទៅដល់ប្រទេសជប៉ុនដូចគ្នា ប៉ុន្តែទើសទាក់លំបាកច្រើន ព្រោះអ្នកស្រុកជប៉ុនមិនស្រឡាញ់កប់អាន ៗ គ្រិស្តសាសនាគ្រាន់តែផ្សាយទៅដល់ប្រទេសជប៉ុនប៉ុណ្ណោះ មិនបានធ្វើឲ្យប្រទេសជប៉ុនមានសេចក្តីរុងរឿងទេ ទើបមិនបានតាំងនៅក្នុងសេចក្តីនិយមកប់អានរបស់ប្រជាជន ដូចជាពុទ្ធសាសនា នឹងសាសនាជិនតោ ដែលមានប្រាកដនៅក្នុងប្រទេសជប៉ុនសព្វថ្ងៃនេះ ៗ

សាសនាពុទ្ធៈនឹងសាសនាជិនតោបានបណ្តុះឧបនិស្ស័យរបស់ប្រជាជនជប៉ុនឲ្យមានសេចក្តីសាមគ្គីព្រមព្រៀងគ្នា មានទឹកចិត្តតែមួយដូចគ្នា មានឆន្ទៈស្មើគ្នាដូច្នេះ បានជាបណ្តាក្សត្រជប៉ុនមានសិទ្ធិនឹងនិយាយបានពេញមាត់ថា "ដែលជាតិគេបានចំរើនដល់កំពូលដ៏ខ្ពស់ ទាល់តែក្លាយទៅជាមហាប្រទេសក្នុងភូមិភាគអាស៊ីទ្វីបនេះ ក៏ព្រោះតែសាសនាទាំងពីរបានឲ្យផល" ហើយនាំគ្នាប្រកាន់យ៉ាងខ្ជាប់ខ្ជួនថា "ព្រះរាជាម្ចាស់ផែនដីរបស់គេក៏គឺជាប់លោហិតរបស់គេ" ៗ ព្រោះហេតុនោះតាំងពីកកើតមានជាតិជប៉ុនឡើងក្នុងលោក មិនដែលមានការផ្លាស់ប្តូរវង្សក្សត្រឡើយ ហើយក៏ចេះតែចំរើនរុងរឿងរហូតដល់សព្វថ្ងៃនេះ ៗ

ចប់

សរណកថា

# លោកអាចារ្យ ឆង-សាមិទ្ធ ពុទ្ធរក្ខិតោ

*គ្រូបង្រៀនបាលីនៅសាលាបាលីរងវត្តលង្កា ក្រុងភ្នំពេញ*

**ទេសនាផាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៣ កេច ខែស្រាពណ៍ឆ្នាំកុរឯកស័ក ព. ស. ២៤៩១ (២២-០៨-៤៧)**

## នមត្ថុ រតនត្តយស្ស

*សូមនមស្ការចំពោះព្រះរតនត្រ័យដោយសង្ខេប*

## សព្វត្ថភយ និវារណត្ថំ

*ដើម្បីការពារនូវសេចក្តីអន្តរាយគ្រប់យ៉ាង ។*

*តអំពីបទនមស្ការនេះទៅ នឹងសំដែងធម៌ទេសនាអំពីពាក្យថា "ទីពឹង" តាមសមគួរដល់កាលវេលា ។*

*បណ្តាមនុស្សក្នុងសកលពិភពលោក ត្រូវតែមានការពឹងពាក់ប្រស្រ័យផាប់ទាក់ទងគ្នាទៅវិញទៅមកជាធម្មតា គឺកូនត្រូវទីពឹងឪពុកម្តាយៗត្រូវទីពឹងកូន, ប្អូនប្រុសស្រីត្រូវទីពឹងបងប្រុសស្រីៗត្រូវទីពឹងប្អូនប្រុសស្រី, អ្នកក្រត្រូវទីពឹងអ្នកមានៗត្រូវទីពឹងអ្នកក្រ, រាស្ត្រត្រូវទីពឹងនាម៉ឺនៗត្រូវទីពឹងរាស្ត្រជាដើម, ឬក៏នាម៉ឺនត្រូវទីពឹងព្រះមហាក្សត្រ, ឯពួកសត្វត្រូវទីពឹងព្រះធម៌, សត្វក្នុងឧទរត្រូវទីពឹងឪពុកម្តាយ*

ទើបរួចអំពីសេចក្តីទុក្ខជួបប្រទះនឹងសេចក្តីសុខ ក្នុងលោកនេះនឹងលោកខាងមុខតាមសមគួរដល់ឋានៈ នឹងកាលៈទេសៈរបស់ខ្លួន ។

## អធិប្បាយពាក្យថាទីពឹង

ពាក្យថា " ទីពឹង " ដែលលោកបញ្ញត្តប្រើក្នុងភាសាខ្មែរនេះ ត្រូវនឹងពាក្យបាលីថា " សរណៈ" សំគាល់សេចក្តីថា " ទីពឹង ទីរឭក ឬ ម្ចប់សម្រាប់ជ្រក " ។

ពាក្យ " ទីពឹង " នេះ ក្នុងភាសាបាលីហៅផ្លាស់ប្តូរគ្នាច្រើនសព្ទៈ ចួនកាលហៅថា " សរណៈ", ចួនកាលហៅថា " ទីបៈ", ចួនកាលហៅថា " នាថៈ" ។ អ្នកដល់នូវទីពឹងនោះហៅថា " សរណង្គតោ, នាថង្គតោ, ទីបង្គតោ " ប្រែថា " អ្នកដល់ឬអ្នកប្រកបដោយទីពឹង " ។ ពាក្យថា " សរណៈ, នាថៈ, ទីបៈ" អម្បាលនេះ គ្រាន់តែផ្សេងគ្នាដោយតួអក្សរ តែសំគាល់សេចក្តីជាមួយគ្នា សំដៅត្រង់ផលប្រយោជន៍ដែលឲ្យសម្រេចសេចក្តីសុខកាយសប្បាយចិត្ត សមប្រកបតាមសេចក្តីប្រាថ្នាដូចគ្នា ។ ឯទីពឹងនោះមាន ៣ យ៉ាង គឺៈ ១ - អាទិសរណៈ = ទីពឹងត្រង់ខាងដើម, ២ - មជ្ឈសរណៈ = ទីពឹងត្រង់កណ្តាល, ៣ - បរិយោសានសរណៈ = ទីពឹងត្រង់ទីបំផុត ។

**ទីពឹងត្រង់ខាងដើម** — មាតាបិតាទុកជាទីពឹងខាងដើមរបស់កូនប្រុសស្រីគ្រប់គ្នា ។ ធម្មតាកូនប្រុសស្រីទាំងឡាយត្រូវតែមានមាតាបិតា

ជាទីពឹងទីរឭក ឬជាម្លប់សម្រាប់ដេក គឺបុត្រធីតាត្រូវតែពឹងពាក់ប្រស្រ័យចំពោះមាតាបិតារបស់ខ្លួនជាអាទិ៍ តាំងតែពីបដិសន្ធិវិញ្ញាណមកចាប់បដិសន្ធិក្នុងផ្ទៃជាដំបូងរហូតប្រសូតចាកគភ៌ ៗ មាតាបិតាកាលបើដឹងជាទារកមកចាប់ក្នុងគភ៌កាលណាហើយ ក៏ស៊ូទ្រាំទ្រពបីគភ៌នោះបំពេញបំប៉នឱ្យមានសាច់ស្បែកឈាមសរសៃជីវិតសង្ខាររស់នៅស្រួល ៗ បំណែកខាងសាច់ស្បែកឈាមសរសៃរបស់លោកដែលទារកជញ្ជក់ជញ្ជប់បៀមបៅ ក៏បេះតែស្រកស្រុតស្គុតអស់អរយៈរាល់ពេលរាល់វេលា, កម្លាំងកំហែង ក៏ថមថយទុរន់ទុរព្វលហល់ហត់ល្ហិតល្ហៃពាបពាប់ទៅនឹងកន្ទួល មានសេចក្តីទុក្ខក្រៀមក្រំដាំដាំនៅក្នុងខ្លួនស្ទើរតែក្សិណក្ស័យជីវិតសង្ខារត្រាតែគ្រប់ខែ ៩ ឬ ខែ ១០ ទើបប្រសូតមក ៗ កាលបើប្រសូតមកក៏បានបីបាច់ថែរក្សាបីបមថ្នមបំពេ មានបញ្ចុកទឹកក្សីរទំចំណីអាហារសព្វទិវារាត្រី នឹងមានទឹកហ្ប៉ុយហូរស្រោចស្រប់ប្រស់ព្រំអប់រំផ្សព្វផ្សាយលើកូនប្រុស-ស្រីជានិច្ច ៗ លុះកូនប្រុសស្រីមានវ័យវឌ្ឍនាការចំរើនធំឡើង បានបណ្តុះបណ្តាំស្រោចស្រង់កូននោះឱ្យរួចផុតអំពីហីនភាពឡើងជាអរិយភាពតែម្យ៉ាង តាំងប្រៀនប្រដៅកូនឱ្យលះបាបធ្វើបុណ្យ ឱ្យសិក្សាវិជ្ជាការសិល្បសាស្ត្រផ្សេងៗ មានលេខនព្វន្តគុណហានឹងត្បាញរវៃដេរប៉ាក់ ចាក់គ្រីបជាដើម ៗ មិនតែប៉ុណ្ណោះ ថែមទាំងរៀបចំឱ្យមានស្វាមីភរិយា ចែកមត៌កទ្រព្យសម្បត្តិព្រមទាំងបង្រៀនកូនប្រុសស្រីឱ្យ

បេះគោរពបូជាចំពោះព្រះមហារាជាធិរាជ ជាសម្មតិទេព ដ៏វិសេសឬជាសរណៈជាម្លប់របស់ប្រជាជាតិគ្រប់គ្នា យ៉ាងនេះហៅថាអាទិសរណៈ ប្រែថា មាតាបិតាជាទីពឹងខាងដើមរបស់កូនប្រុសស្រី ។

**ទីពឹងត្រង់កណ្ដាល** – ព្រះមហាក្សត្រគ្រប់ព្រះអង្គជាទីពឹងទីរឭកត្រង់កណ្ដាលរបស់ប្រជាជនគ្រប់គ្នា ទាំងខាងក្នុងនិងខាងក្រៅព្រះរាជនគរ ។ ធម្មតានគរមួយៗ លុះត្រាតែមានព្រះមហាក្សត្រជាអធិបតី ព្រះមហាក្សត្រជាបិតា ព្រះមហាក្សត្រជាសម្មតិទេពឬជាសរណៈទីពឹងទីរឭក ទើបនគរនោះសម្បូណ៌សប្បាយដោយវត្ថុផ្សេងៗ និងជាទីរីករាយសប្បាយដល់ប្រជាជនគ្រប់គ្នា លឿនសស្រឹមទៅកាន់អារ្យធម៌អស់កាលជានិច្ច ប្រាសចាកទុក្ខទោសអន្តរាយទាំងអស់ ជួបប្រទះសេចក្ដីសុខចំរើនគ្រប់ប្រការ ។ ព្រោះហេតុនោះ ព្រះសាស្ដាចារ្យទ្រង់សាងនគររបស់ព្រះអង្គឲ្យមានរបៀបរៀបរយយ៉ាងត្រកាល មានព្រះទ័យត្រជាក់ត្រជំដូចទឹកស្រះអនោតត្ត មានព្រះទ័យស្មោះស្ម័គ្រប្រកបដោយទសពិធរាជធម៌សព្វគ្រប់ប្រការ ព្រះអង្គជាទីពឹង ជាទីពំនាក់ក៏ក្រអាស្រ័យ ប្រកបដោយព្រះធម៌សព្វគ្រប់ប្រការ ប្រកបដោយមហាករុណា ជាអ្នកសម្រេចសេចក្ដីប្រាថ្នាដល់សព្វសត្វគ្រប់ប្រាណ, ដល់ពេលជាអវសានព្រះអង្គក៏បានលះបង់ព្រះរាជបុរីដ៏ថ្លៃថ្លា ដែលបរិបូណ៌ដោយមហាសម្បត្តិ ទ្រង់លះកាត់ព្រះរាជបុត្រព្រមទាំងព្រះរាជវង្សានុវង្ស និងមហាសម្បត្តិ

ប្រកបដោយកែវ ៧ ប្រការនឹងស្វេតច្ឆ័ត្រ ព្រះអង្គទ្រង់លះកាត់ផាច់អាល័យ ឥតមានសេចក្ដីប្រាថ្នា យាត្រាចេញទៅសាងមហាភិនិស្ក្រមសម្បំនៅក្នុងព្រៃស្ងាត់ស្វែងរកមគ្គផលជាបរមត្ថ មហាប្រសើរ ទ្រង់ផ្ចង់បន្ថយបង្ហើរពោលនូវលតាវល្លិដែលដុះលូនច្ចងប្រទាក់គ្នាគឺមិច្ឆាទិដ្ឋិ, រំលើងបង់នូវទីនៅអាស្រ័យនៃលតាវល្លិគឺបញ្ចកាមគុណ, កាត់បង់នូវៈលោភៈទោសៈ មោហៈ ទាំងឡាយ, ហាមបង់នូវព្រៃនៃតណ្ហា, បិទផ្លូវខុសបើកផ្លូវត្រូវ ដោះពួកប្រជាជនឲ្យរួចអំពី ចំណោមនៃសេចក្ដីទុក្ខព្រួលសេចក្ដីសុខបញ្ចាលក្នុងវដ្ដតវរបស់ព្រះអង្គ ។ យ៉ាងនេះហៅថា មជ្ឈសរណៈ = ទីពឹងត្រង់កណ្ដាល ។

**ទីពឹងត្រង់ទីបំផុត** – បណ្ដាមនុស្សទេវតាក្នុងសកលពិភពឋានត្រូវមានសាសនាសម្រាប់ប្រដៅគ្រប់ប្រាណ ដល់អវសានយើងនឹងបានសេចក្ដីសុខឥតទុក្ខភ័យចង្រៃរោគពុះបង្ទ្រប់គ្រប់ប្រការ ត្រូវមានសាសនាជាប្រមុខ, សាសនាជាម្ចប់សម្រាប់ដឹកបានត្រជាក់ក្នុងលោកនេះនឹងលោកខាងមុខ សាសនាជាបន្ទាត់ សាសនាជាប្រទីបសម្រាប់ត្រោលបំភ្លឺ សាសនាជាបង្កិតរបស់សកលរដ្ឋ ឬសកលលោក ។ ដូចជាយន្តទាំងឡាយដែលប្រកបដោយគ្រឿងទព្វសម្ភារៈផ្សេងៗ បើគ្មានបង្កិតសម្រាប់ដម្រង់ទេ ក៏មិនអាចបើកឲ្យលឿនទៅកាន់ទីប្រាថ្នាបាន យ៉ាងណាមិញ; សកលលោក បើគ្មានសាសនាក៏មិនអាចលឿនទៅបាន លុះតែមានសាសនាជាបង្កិត ទើបលឿនទៅកាន់អារ្យធម៌ជានិច្ចបាន ដូច្នោះដែរ ។

ហេតុនេះ ប្រជាជនចូរស្រឡាញ់សាសនាគ្រប់គ្នាចុះ ។ សាសនានោះមាន ២ យ៉ាង គឺ: ១– ពាហិរសាសនា = សាសនាខាងក្រៅ, ២– ពុទ្ធសាសនា = សាសនាព្រះពុទ្ធ ។ ក្នុងទីនេះ សូមសម្ដែងតែអំពីពុទ្ធសាសនាដែលជាសាសនាឯកក្នុងលោក ។

“ពុទ្ធ” ក្នុងទីនេះ បានដល់អរិយជន ១ អង្គ ដែលកើតនៅក្នុងមជ្ឈ-មប្រទេស ជាខត្តិយត្រកូល អរិយជាតិ ឬជាអរិយែន ជាគោត្តមគោត្រ ។ ព្រះអង្គជាបុគ្គលអស្ចារ្យក្នុងលោកគ្មានអ្នកណាមួយប្រៀបផ្ទឹមស្មើ ត្រាស់ដឹងសព្វគ្មានបន្ទោះ មនុស្សសត្វទេពតាតែងគោរពបូជាកោតខ្លាច ថ្វាយព្រះនាមថា “ព្រះពុទ្ធ:” ។

ពាក្យប្រៀនប្រដៅរបស់ព្រះអង្គហៅថា “ពុទ្ធសាសនា” អ្នកប្រព្រឹត្តតាមពុទ្ធឱវាទហៅថា ពុទ្ធសាសនិកនិកាយ “ពួកអ្នកកាន់សាសនាព្រះពុទ្ធ ឬ ពួកអ្នកចូលសាសនព្រះពុទ្ធ” ។

អ្នកកាន់សាសនាព្រះពុទ្ធ ត្រូវបានប្រយោជន៍គឺសេចក្ដីសុខក្នុងជាតិនេះនឹងជាតិខាងមុខ ; ប្រយោជន៍ក្នុងជាតិនេះ ត្រូវទទួលសម្បត្តិ ៣ យ៉ាងគឺ បានរូបសម្បត្តិល្អ មកពីរក្សាសីល ១, មានទ្រព្យសម្បត្តិច្រើន មកពីឲ្យទាន ១, មានប្រាជ្ញាច្រើន មកពីចំរើនមេត្តាភាវនា ១ ។

មួយទៀតបុណ្យនឹងបាបនេះ រមែងជាប់ដិតជាមជាមួយនឹងចិត្ត សម្រេចមកអំពីចិត្ត ដល់ពេលស្លាប់ទៅនឹងតាមឲ្យផលក្នុងជាតិខាងមុខ

ទៀត ដូចជាម៉ាស៊ីនសម្រាប់ថត បើម៉ាស៊ីនល្អ - អាក្រក់ - ធំ - តូច រូបថតក៏ល្អ - អាក្រក់ - ធំ - តូចតាមម៉ាស៊ីននោះដែរ; ម៉ាស៊ីនទុកដូចជាតួចិត្ត ស្រមោលរូបថតទុកដូចជាតួបុណ្យនឹងបាប; រូបរបស់អ្នកណានៅជារបស់អ្នកនោះមិនផ្លាស់ប្តូរ គ្រាន់តែមួយរូបចាស់មួយរូបថ្មីប៉ុណ្ណោះ ៗ មិនត្រឹមតែប៉ុណ្ណោះ តាមទៅប្រគល់សេចក្តីសុខទុក្ខ បំរើនវិនាសអាក្រក់ល្អ តាមលំដាប់ជាតិទៀត ដូចបុរាណកាសិតថា "ដូចជាស្រមោល អន្ទោលតាមប្រាណ ពុំដែលចៀសបាន ត្រង់ក្តីសល់រលំ" ៗ មែនពិត ស្រមោលទោះបីគេដេរស៊ីបណ្តេញបំបរ ឬលួងលោមអង្វរថា "សូមឲ្យស្រមោលឯងត្រឡប់វិញ" ដូច្នេះ ដោយពាក្យពីរោះក្តី. ពុំពីរោះក្តី ស្រមោលក៏មិនស្តាប់ រេះតែទៅតាមប្រាណ បើមនុស្សដេកស្រមោលក៏ដេក បើមនុស្សដើរ ស្រមោលក៏ដើរតាម គ្រប់តិរិយាបថយ៉ាងណាមិញ បុណ្យនឹងបាបក៏ដូច្នោះដែរ ស្រមោលទុកដូចជាបុណ្យបាប, មនុស្សដេកដើរឈរអង្គុយ ទុកដូចជាមនុស្សស្លាប់ឬនៅរស់នៅឡើយ រមែងតាមប្រគល់ឲ្យផលបុណ្យផលបាប ដល់មនុស្សនោះគង់ជាតិនេះនឹងជាតិខាងមុខជានិច្ច ៗ ព្រោះហេតុនោះ សាធុជនទាំងឡាយត្រូវនាំគ្នាខ្វល់ខ្វាយលះអំពើបាប បំពេញអំពើបុណ្យ ដើម្បីជាទីពឹងឬជានិស្ស័យបច្ច័យរាសនារបស់ខ្លួនទៅជាតិមុខទៀត ៗ នេះហៅថា បរិយោសានសរណៈ= ទីពឹងត្រង់ទីបំផុត ៗ

មែនពិត មនុស្សគ្រប់សកលពិភពលោក ត្រូវតែស្វែងរកទីពឹងទាំង ៣ ប្រការនេះ, មុនដំបូងត្រូវទីពឹងឪពុកម្ដាយ ទី ២ ត្រូវទីពឹងព្រះមហាក្សត្រ ទី ៣ ត្រូវទីពឹងសាសនា គឺថាត្រូវស្រឡាញ់មាតាបិតាសាសនាមហាក្សត្ររបស់ខ្លួន ។

ឯមាតាបិតា, សាសនា, មហាក្សត្រ លោកទុកជាបុព្វការី របស់ប្រជាជនគ្រប់គ្នា ព្រោះលោកមានគុណូបការ ជាអនេកអនន្តជូនពន់ប្រមាណណាស់ សូម្បីតែវិកនពូមហាសមុទ្រក្ដី ផែនក្រឡាមហាប្រថពីក្ដី ក៏មិនយកមកប្រៀបឲ្យស្មើនឹងគុណនោះពុំបាន ។ អ្នកណាមួយមិនគោរពប្រតិបត្តិស្រឡាញ់រាប់អានមាតាបិតាសាសនាមហាក្សត្ររបស់ខ្លួនទេ អ្នកនោះគេហៅថា ស្អប់ឬក្បត់ចិត្ត ឬហៅថា អកតញ្ញូ ជាអ្នកមិនដឹងគុណនៃជាតិទឹកដីសាសនាមហាក្សត្ររបស់ខ្លួនដោយពិត ។ ព្រោះមាតាបិតាលោកជាអ្នកបង្កើតកូន ឬជាអ្នកសាងជាតិកំណើតឲ្យកូន, ព្រះមហាក្សត្រជាអ្នកសាងច្បាប់សម្រាប់ប្រជាជាតិ ឯព្រះលោកនាថជាអ្នកប្រកាសព្រះធម៌ទុកសម្រាប់ប្រជាជនគ្រប់ត្រកូល ។

សំដែងមកក្នុង សារណកថា សន្តថាចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

ដោយអំណាចនៃធម៌ទេសនានេះ សូមសត្វទាំងឡាយដល់នូវសេចក្ដីក្សេមក្សាន្តគ្រប់ប្រាណទៅហោង ។

ចប់

ការបណ្ដុះនិស្ស័យ

# ព្រះមហាឧត្តមវិជា ផលញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវត្តី ក្រុងភ្នំពេញ រៀបរៀង

## យុគបណ្ណាធរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ ពិនិត្យកែ

(តមក)

---

មនុស្សយើងនឹងទៅជាមនុស្សល្អបាន ត្រូវតែកសាងថ្នាក់ឋានគោលទីតាំង ៤ កាលវ័យនៅក្មេង ត្រូវតាំងចិត្តសិក្សាវិជ្ជាឲ្យបានច្រើន ហើយឲ្យចេះពិតៗផង កុំធ្វើចិត្តធេវធាវប្រញាប់ទុំមុនស្រគាល ; កាលធំឡើងត្រូវព្យាយាមស្វែងរកទ្រព្យតាមផ្លូវសុចរិត តាំងគេហស្ថានផ្ទះសំបែងឲ្យមានទីតាំងមាំមួន ប្រព្រឹត្តខ្លួនតែក្នុងសីលធម៌ ធ្វើខ្លួនឲ្យជាមនុស្សស្លុតស្លូតមានបក្សពួកកៀនកក្ដិល្អច្រើន ដំណើរជីវិតទៅឲ្យសមគួរដល់ឋានៈរបស់ខ្លួន កុំធ្វើចិត្តស្រាល បានបន្តិចកំប៉ិចឡើងហួសឋានៈរបស់ខ្លួន ដែលជាហេតុនាំឲ្យឋានៈនោះរលំរលាយបាត់ទៅវិញ ត្រូវប្រព្រឹត្តតាមគោលខាងក្រោមនេះ គឺ :

ក – <u>ត្រូវមានផ្ទះសំបែងឲ្យមាំមួន</u> – គឺមានទីនៅអាស្រ័យជាគស្សរៈពេញលេញ ហើយលំនៅនោះនៅក្នុងកម្មសិទ្ធិរបស់ខ្លួនឯង ឬជាទីដែលមនុស្សដទៃឲ្យនៅអាស្រ័យឬក៏យើងជួលនៅអាស្រ័យបិតថេរក៏ដោយ តែកាលមាននរណាមួយ ដែលគ្នាទីទាល់ក្រជាប់ទាក់ទងនឹងយើង យើង

កំអាចជួយអនុគ្រោះឲ្យគ្នានៅផងបានដោយងាយ កុំជាមនុស្សចេះតែដើរនៅផ្តេសផ្តាស មិនមានទីលំនៅប្រាកដប្រជា ។

ខ. — ត្រូវមានគ្រួសារមាំមួន — បើបុរសត្រូវមានភរិយា បើជាស្ត្រីត្រូវមានស្វាមីឲ្យពិតប្រាកដ ចងមេត្រីស្រឡាញ់រួមរក្សាគ្នាដោយសុចរិតស្មោះត្រង់ រាប់អានលើកដំកើងគ្នាជាគូសាងបារមី នាំគ្នាជួយបណ្ដាះបាន: ឲ្យមានគោលទីតាំង ចិញ្ចឹមគ្នាទៅវិញទៅមកដោយត្រឹមត្រូវតាមប្រវេណីរហូតដល់អស់ជីវិត ។ កុំជាមនុស្សមានភរិយាស្វាមី គ្រាន់តែដើម្បីបំពេញសេចក្តីត្រេកត្រអាល ឬដើម្បីបង្ហិនទ្រព្យសម្បត្តិគ្នាអស់ហើយកំលះលែងគ្នា, ទាំងកុំជាមនុស្សមានភរិយាស្វាមីដោយប្រាថ្នានឹងយកបាយបរិភោគក្នុងពេលថ្ងៃៗនោះឡើយ ។ បើជាមនុស្សមិនមានភរិយាស្វាមីទេ កំត្រូវមានវង្សញាតិឬមនុស្សបំរើក្នុងផ្ទះយ៉ាងមាំមួនជារបៀបរៀបរយ, កុំជាមនុស្សអនាថាប្រាសចាកគ្រួសារ ។

គ. — ត្រូវមានរបរចាជីវកម្ម ហត់ចត់ប្រាកដប្រជា — កាលនៅក្នុងទីណា ត្រូវគិតតាំងខ្លួនរបស់ខ្លួនឯង ឲ្យមានគោលទីតាំងក្នុងទីនោះ កុំប្រាថ្នាចំពោះសេចក្តីឧបត្ថម្ភ ផ្គុំផ្តើមអំពីអ្នកដទៃតែ១ ចំណែកឡើយ, ត្រូវតាំងចិត្តបរិភោគតែអាហារដែលកើតឡើង ដោយសារញើសឈ្អួលរបស់ខ្លួនឯង ។ ការទៅប្រដុំជួយបរិភោគអាហារដោយសារការងាររបស់អ្នកដទៃតែម្យ៉ាង មិនប្រពៃឡើយ, ត្រូវតាំងខ្លួនឲ្យមានគោលទីតាំង

ឲ្យមានផ្ទះសម្បែងជារបស់ខ្លួន ឲ្យមានទីដីជារបស់ខ្លួន. ត្រូវធ្វើការអាជីវៈដែលជាគោលនៃទ្រព្យ ដូចជាធ្វើស្រែចំការ ច្បារដំណាំ ឲ្យមាំទាំជាដើម ប្រកបការងាររបស់ខ្លួនតាមកំឡាំងខ្លួន ឲ្យជាដុំជាកំភួន ដើម្បីញ៉ាំងភោគទ្រព្យឲ្យកើតឡើងដល់ខ្លួននឹងប្រទេសជាតិ ធ្វើឲ្យខ្លួននឹងគ្រួសារបាននៅជាស្រួល បរិភោគជាស្រួល មានមុខមាត់ជាកិត្តិយសឡើង ។

ឃ.– <u>ត្រូវដាក់ខ្លួនទុកឲ្យត្រូវ</u> – គោលសំខាន់នៃការដាក់ខ្លួនឲ្យត្រូវនោះ នៅត្រង់ការមិនធ្វើអំពើដែលគាប់ចិត្តតែមនុស្សម្នាក់ខ្លួនឯងម្នាក់, នៅត្រង់ការព្យាយាមធ្វើអំពើដែលមនុស្សល្អធ្វើច្រើន, នៅត្រង់ការធ្វើអំពើដែលគាប់ចិត្តរបស់មនុស្សល្អច្រើនគ្នា ។ ហេតុនេះយើងត្រូវប្រព្រឹត្តខ្លួនឲ្យល្អ ឲ្យមានសីលធម៌ ឲ្យសុចរិត មិនឲ្យខុសច្បាប់ទំលាប់ផែនដី នឹង ឲ្យជាបុណ្យកុសលដាក់ខ្លួនទុកឲ្យត្រង់ កុំឲ្យវង្វេងខុសគោលធម៌ ដូចជាកុំប្រព្រឹត្តខ្លួនឲ្យជាមនុស្សមុខរឹង ចិត្តឃោរឃៅជាដើម កុំឆបោក កុំទទួលទិញរបស់ចោរ កុំទទួលស៊ីឈ្នួលគេដើម្បីធ្វើការដែលមានទោស កុំទទួលសំណូក កុំធ្វើមាសប្រាក់ក្លែងក្លាយ កុំទិញលក់របស់ព្រៃ គឺរបស់គេចពន្ធឬគេចគយ កុំបំបាត់ពស្ត្រ កុំបំបាត់រាជការ កុំជាមនុស្សមូទូលេងស្រា លេងស្រីនឹងល្បែងទាំងពួងដែលជាអបាយមុខ ចូរព្យាយាមបង្កើនការងារដែលល្អៗ ក្នុងមុខក្រសួង នឹង ព្យាយាមអប់រំ

វិជ្ជាដែលចេះស្រាប់ហើយឲ្យនៅគង់វង្ស នឹង ខំបន្ថែមវិជ្ជាថ្មីឲ្យរឹងរឹតតែចំរើនឡើងជាភិយ្យោភាព ។

កាលយើងតាំងខ្លួនឲ្យមានផ្ទះសម្បែង ជាទីសំណាក់អាស្រ័យមាំមួន មានគ្រួសារមាំទាំ មានការអាជីវៈជាគោលសំខាន់នឹងដាក់ខ្លួនឲ្យត្រូវយ៉ាងនេះហើយ យើងក៏នឹងទៅជាមនុស្សល្អ មានគោលជាទីតាំងបាន ។ តែបើយើងមិនមានឋានៈដូចពណ៌នាមកនេះទេ សូម្បីយើងនិយាយថា "ខ្ញុំជាមនុស្សល្អ" ក៏នឹងទៅជាមនុស្សល្អមិនបានឡើយ ។

**៨ - អ្នកល្អ តែងចេះគ្រប់គ្រងខ្លួនឯង** — គឺចេះដាស់តឿនខ្លួនឲ្យដឹងខុសត្រូវចំពោះខ្លួនឯង កាលធ្វើខុសក៏ដឹងថាខុស តិះដៀលខ្លួនឯងក្នុងកាលដែលក្លែងធ្វើឲ្យខុស នឹង ចេះប្រមាណខ្លួនថា មានជាតិត្រកូលយសស័ក្តិទ្រព្យសម្បត្តិ សមត្ថភាព ចំណេះវិជ្ជានិងគុណធម៌ត្រឹមថ្នាក់ណា ហើយក៏តាំងខ្លួនឲ្យសមគួរដល់ឋានៈនោះៗ ទាំងចេះរាប់អានខ្លួនឯង មិនជិះជាន់ខ្លួនឯង មិនបំរុញខ្លួនឲ្យធ្លាក់ទៅក្នុងទីអាក្រក់ ចេះជួយខ្លួនឲ្យផុតចាកសេចក្តីអាក្រក់ មិនធ្វើអាក្រក់ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ប្រកាន់អំពើអាក្រក់ថាជាការមើលងាយសង្កត់សង្កិនខ្លួនឲ្យធ្លាក់ចុះទៅកាន់ទីទាប ធ្វើខ្លួនឲ្យជាទីមើលងាយនៃមនុស្សដទៃ, ចេះទទួលខុសត្រូវខ្លួនឯង ធ្វើខ្លួនឲ្យតាំងនៅក្នុងបណ្តាប់របស់ខ្លួនឯង, ត្រួត

ត្រាខ្លួនឯងជានិច្ចដើម្បីការពារខ្លួន និង ចេះពិចារណាពិគ្រោះមើលឲ្យឃើញថា អ្វីគួរ អ្វីមិនគួរ ។

តាមពិត អ្នកដែលមានសមត្ថភាព អាចត្រួតត្រាប្រទេសបានពេញទាំងផែនដី ក៏នៅតែមិនទាន់សំខាន់ស្មើនឹងអ្នកដែលត្រួតត្រាខ្លួនឯងបានដែរ, ការឈ្នះខ្លួនឯងនេះប្រសើរណាស់ ត្រូវនឹងព្រះពុទ្ធភាសិតថា អត្តា ហវេ ជិតំ សេយ្យោ "ការយកឈ្នះខ្លួនឯងបាន ជាការប្រសើរណាស់" ។

ដូច្នេះ យើងត្រូវតែធ្វើខ្លួនឲ្យជាអ្នកល្អខាងការចេះគ្រប់គ្រងខ្លួនឯងផង កុំធ្វើខ្លួនឲ្យជាមនុស្សថោកទាប គឺកុំសេពគប់តែនឹងមនុស្សមិនបានការ ជាអ្នកដើរផឹក ដើរស៊ីជក់ផ្តេសផ្តាស ជាអ្នកលេងល្បែងភ្នាល់នឹងលេងស្រី, ត្រូវធ្វើខ្លួនឲ្យជាមនុស្សល្អ ប្រកបអំពើដែលគួរប្រកប វៀរអំពើដែលគួរវៀរ, ធ្វើ និយាយ គិតអ្វី ក៏ឲ្យជាទីទុកចិត្តនឹងល្មមជឿ ល្មមកាន់យក ឬមិនជាទីរង្កៀសសង្ស័យរបស់មនុស្សដទៃ, កុំធ្វើខ្លួនឲ្យជាទីមើលងាយនៃមនុស្សទាំងពួងនឹងជាទីនាំឲ្យខូចកេរ្តិ៍ឈ្មោះ ឬគុណធម៌របស់ខ្លួន, កុំនិយាយកុហក ក្លែងទំលាក់ទោសឬរំលោភលើអ្នកដទៃ ដើម្បីកែខ្លួនឲ្យផុតចាកពិរុទ្ធណាមួយ ឬក៏ដើម្បីរក្សាកិត្តិយសរបស់ត្រកូលរបស់គណៈ ឬរបស់ជាតិ កុំឲ្យកើតសេចក្តីវិនាស ព្រោះខ្លួនឯងបាននោះឡើយ ។

បើយើងជាអ្នកតូច គួរធ្វើខ្លួនឲ្យសមនឹងភាពជាអ្នកតូច ជឿស្តាប់ពាក្យបង្គាប់របស់អ្នកបង្គាប់បញ្ជា, កុំចាប់ថ្នាក់អ្នកធំ ក្នុងកាលដែលលោក

ភ្លាត់ខុស, អត់ធន់ចំពោះសេចក្ដីនឿយហត់, សូម្បីខ្លួនយើងចេះដឹងច្រើនជាងប្អូន និងអ្នកធំក៏ដោយ ក៏កុំប្រព្រឹត្តប្រឆេងប្រឆាំងកណ្ដាលជំនុំឬក៏រាយប្ញកអំណាចស្មើនឹងអ្នកធំឡើយ, បើនឹងសាកសួរប្រឹក្សា ឬសូមមតិឬក៏បញ្ចេញគំនិតរបស់ខ្លួនចំពោះអ្នកធំ ក៏ចូររវាំងប្រយ័ត្ន កុំណែនាំឲ្យអ្នកធំឡើងជំនោរអួតគុណសេចក្ដីល្អ ហើយមើលងាយគេឬប្រាជ្ញាធំឡើងហួសយសសក្ដិនោះឡើយ ព្រោះជាហេតុបង្វែរចិត្តអ្នកធំឲ្យចេះស្អប់គេឯងលែងមានមេត្តាករុណាចំពោះអ្នកដទៃ, ចូរយើងសំដែងខ្លួនជាអ្នកស្ងប់ស្ងៀមប្រដៅងាយ មានកិរិយាពាក្យសម្មាគារវៈឲ្យអ្នកធំចេះស្រឡាញ់រាប់អាន មានមេត្តាករុណាប្រាថ្នាសេចក្ដីចំរើនចំពោះអ្នកដទៃ និង ជួយលើកដំកើងសរសើរអ្នកដទៃដោយសុចរិតពិតៗ ។

៩ **អ្នកល្អ តែងចេះគ្រប់គ្រងមនុស្សដទៃ** - មនុស្សយើងតែងនៅរួមគ្នាជាពួកគណៈជាទិចៗ ។ ក្នុងពួកគណៈមួយៗ រមែងមានទាំងអ្នកធំទាំងអ្នកតូច ហើយតែងមានសុខទុក្ខ វិនាសចំរើន ជាប់ទាក់ទងនឹងគ្នា ។ អ្នកតូចត្រូវនៅក្នុងការគ្រប់គ្រងរបស់អ្នកធំ មានអ្នកធំជាទីពឹង ។ អ្នកធំត្រូវគ្រប់គ្រងអ្នកតូច និងអាស្រ័យអ្នកតូចជាកំឡាំង ។ តែការគ្រប់គ្រងអាចនឹងរៀបរយបាននោះ លុះតែអាស្រ័យមធ្យោបាយដ៏ប្រពៃផង ។ អ្នកល្អរមែងចេះគ្រប់គ្រងមនុស្សដទៃ ។ យើងនឹងទៅជាមនុស្សល្អ ត្រូវចេះគ្រប់គ្រងមនុស្សដោយឧបាយដ៏ឈ្លាសវៃដូចតទៅនេះ:

ក. — បើយើងមាននាទីជាអ្នកគ្រប់គ្រងមនុស្ស ចូរតាំងខ្លួនជាអ្នកធំប្រាសចាកអគតិ មានសេចក្ដីទៀងត្រង់ជាគោលរបស់ចិត្ត មានមេត្តាករុណា មុទិតា ឧបេក្ខាជាផ្លូវនៃអធ្យាស្រ័យ, ធ្វើការណាមួយ ចំពោះនរណាៗ ចូរកុំលំអៀងព្រោះស្រឡាញ់ស្អប់ខ្លាចនឹងល្ងង់ខ្លៅ, កុំប្រកាន់ថាគេថាយើងឡើយ ព្រោះជាហេតុនាំឲ្យទៅជាមនុស្សក្រអឺតក្រទម, កុំប្រើអំណាចឆេវឆាវតូងតាង កុំគុំគួនបញ្ញុះញង់ឲ្យអ្នកតូចបែកបាក់គ្នា ចូរធ្វើយុត្តិធម៌ឲ្យបានស្មើភាគគ្នាក្នុងរវាងអ្នកតូច ចូរអត់ទុនចំពោះអ្នកតូច ឬអ្នកដែលស្មើគ្នា កុំធ្វើឫកធំទាល់តែអ្នកតូចមកនៅចំពោះមុខមិនបាន ចូរបេះសម្រាលទុក្ខធុរៈអ្នកតូចនឹងមានកលឧបាយដ៏ប្រពៃ ល្មមឲ្យអ្នកតូចដែលនៅក្រោមបង្គាប់បញ្ជាគោរពរាប់អានបាន ។

ខ. — កុំបៀតបៀនអ្នកតូច ត្រូវយកចិត្តគេមកប្រៀបនឹងចិត្តយើង គិតដល់ទ្រូងគេទ្រូងយើង កុំសំឡឹងឃើញតែលាភសក្ការៈដែលបានមកដោយធ្វើឲ្យអ្នកតូចក្ដៅក្រហាយចិត្ត កុំទំលាក់កំហុសរបស់ខ្លួនទៅលើអ្នកតូច កុំបង្ហិនបង្ហោច បង្ខូចប្រយោជន៍ឬសេចក្ដីសុខរបស់អ្នកដទៃ កុំធ្វើការព្រោះសំឡឹងឃើញប្រយោជន៍ផ្ទាល់ខ្លួន ត្រូវគិតដល់ប្រយោជន៍របស់អ្នកដទៃផង ត្រូវធ្វើតែកិច្ចការណា ដែលប្រយោជន៍របស់ខ្លួនក៏សម្រេច ប្រយោជន៍របស់អ្នកដទៃក៏មិនខូច គឺធ្វើការងារដែលមិនប៉ះពារទៅលើសេរីភាពរបស់អ្នកដទៃ ។

គ. — ត្រូវឲ្យមានចិត្តអាណិតមេត្តាចំពោះអ្នកធំអ្នកតូច ទាំងក្នុងរាជការទាំងក្នុងការងារផ្សេងៗ រហូតដល់ញាតិសន្តាន អ្នកស្រុក អ្នកភូមិ រានផ្សារផងទាំងពួង កុំឲ្យបែកបាក់គ្នាឬប្រកួតប្រកាន់គ្នា ចេះថ្នមចិត្តរបស់គេ មិនធ្វើទៅតាមតែអំពើចិត្តខ្លួន ជាមនុស្សចិត្តធ្ងន់ មិនជាមនុស្សត្រចៀកកក់ ចិត្តស្រាលឆាប់ខឹង ។

ឃ. — ត្រូវចេះធ្វើខ្លួនឲ្យសមគួរ គឺចេះដាក់ខ្លួន និង ចេះប្រព្រឹត្តខ្លួនចំពោះអ្នកធំអ្នកតូចនិងអ្នកស្មើគ្នា រហូតដល់ញាតិសន្តាន មនុស្សបំរើ មិត្តសំឡាញ់និងភ្ញៀវក្នុងស្រុកឲ្យសមគួរដល់ឋានៈ គឺនរណាគួរនិងធ្វើស្និទ្ធស្នាល ជឿស្ដាប់បង្គាប់ ឬគួរចៀសវាង នរណាគួរបង្គាប់បញ្ជា-ប្រើឲ្យធ្វើកិច្ចការថ្នាក់ណា ហើយក៏ចាត់ឲ្យធ្វើតាមសមគួរដល់ភូមិជាន់របស់បុគ្គលនោះៗ ។

ង. — ត្រូវចេះរក្សាចិត្តអ្នកតូច ដូចយ៉ាងសំដែងមេត្តា ករុណា ឲ្យរបស់របរ និយាយប្រស័យរាក់ទាក់ ធ្វើទឹកមុខរីករាយស្រស់ស្រាយ ញញឹមញញែមជាដើមទៅរកអ្នកតូច ដើម្បីឲ្យគេបានសេចក្ដីរីករាយចិត្ត, កុំធ្វើបុក ឬដំឡើងអំណាចសំដែងសេចក្ដីកាចសាហាវ ចូរថែរក្សាទឹកចិត្តគេ ឲ្យខំធ្វើការងារតាមនាទីដោយសេចក្ដីពេញចិត្តនិងប្រាថ្នាប្រយោជន៍សេចក្ដីចំរើន ស្មោះត្រង់ចំពោះមុខក្រសួងពិតៗ ។

កិច្ចទាំង ៥ យ៉ាងនេះជាទំនៀមរបស់អ្នកល្អ; យើងគប់គ្នា មិនថាជាន់ណាថ្នាក់ណាឡើយ បើប្រតិបត្តិតាមដោយត្រឹមត្រូវហើយ ក៏ក្លាយ

ទៅជាអ្នកល្អបានទាំងអស់គ្នា ព្រោះយើងធ្លាប់បានឮមកខ្លះហើយថា "អ្នកល្អត្រឡប់ធ្លាក់ខ្លួនទៅជាមនុស្សអាក្រក់ក៏មាន មនុស្សអាក្រក់ត្រឡប់តាំងខ្លួនឡើងជាមនុស្សល្អបានក៏មាន" ។ ត្រង់នឹងបុកណាស់ុភាសិតថា "ឃ្លោកលិចអម្បែងអណ្តែត" ។ ពាក្យនេះមិនខុសពីអ្នកដែលកើតក្នុងត្រកូលទាប ហើយត្រឡប់តាំងខ្លួនឲ្យជាអ្នកខ្ពស់ល្អ មានគេរាប់អានច្រើននោះទេ ព្រោះគេបានប្រព្រឹត្តឲ្យត្រូវត្រង់តាមច្បាប់ប្រវេណីនៃត្រកូលអ្នកល្អ ប្រៀបដូចអម្បែង ពិតមែនតែជារបស់លិចទឹក តែកាលបើមានប្រហោងធំនៅខាងក្នុងមានរបស់អណ្តែតទឹកនៅទ្រផង ក៏អាចអណ្តែតបាន ។ ចំណែកអ្នកដែលកើតក្នុងត្រកូលខ្ពស់ហើយត្រឡប់ទៅជាមនុស្សថោកទាបវិញនោះ ក៏ព្រោះតែខ្លួនប្រព្រឹត្តឲ្យខុសច្បាប់ទំលាប់របស់ត្រកូលអ្នកល្អ ប្រៀបដូចឃ្លោក សូម្បីជារបស់អណ្តែតទឹក តែបើធ្លុះធ្លាយមានប្រហោងជុំវិញ ល្មមទឹកចូលទៅបានហើយ ក៏លិចទៅក្នុងទឹកមិនខានដែរ ។

ដូច្នេះ មនុស្សប្រុស-ស្រីទាំងឡាយ ! ពេលនេះ សូមលោកនឹកក្នុងខ្លួនលោកថា "យសសក្តិដូចយល់សប្តិ រូបឆោមលោមពណ៌ដូចផ្កាឈើ ជីវិតដូចផ្គរបន្ទោរ" ត្រូវកុំកាន់យករបស់អម្បាលនេះជាគ្រឿងអាងថា ខ្លួនជាអ្នកល្អ និង កុំបណ្តែតបណ្តោយខ្លួនដោយអាងថាជាមនុស្សថោកទាបឡើយ ។ ប្តូរមានមារយាទល្អ មានចិត្តល្អ មានសេចក្តី

ស្មោះត្រង់ មានសេចក្ដីសុចរិត រក្សាកិត្តិយស ស្រឡាញ់សន្តិសុខ តាំង គោលចារឹក ទឹង បេះត្រប់ត្រង់ខ្លួនហេតុដល់អ្នកដទៃឲ្យបានកុំខាន ។ ច្បាប់នេះ បើលោកអ្នកធ្វើតាមបានពេញលេញល្អហើយ ក៏នឹងប្រកាស ខ្លួនឲ្យមនុស្សគ្រប់លោកដឹងថា "ខ្លួនលោកអ្នកជាមនុស្សល្អ មាននិស្ស័យ ជាអ្នកល្អ" ពិតមែន ។

សូមក្រមញាតិ ជាតិខ្មែរ សែធ្លាយជិត
ទំរិះគិត ធ្វើប្រាណ ឲ្យបានល្អ
ហើយជួយផ្សាយ រឿងនេះ ទៅតៗ
អ្នកចង់ល្អ បានដឹង គង់ធ្វើតាម ។
ទាំងអ្នកធំ ក៏សូម តាំងចិត្តស
ប្រព្រឹត្តល្អ ទៀតទេ ដែលលោកហាម
ដើម្បីជន សម្ពាយ ងាយធ្វើតាម
គោលបំកម ដែលយើង ណែនាំអើយ !!!

(មាឌត)

អ៊ីទេឡូណា ៖ សិម្ប៉ាណា

រឿងព្រេងប្រទេសរូម៉ានី

## លោក ផេង-ជ្រីវ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង (តមក)

នាងពៅសួរថា: ចុះត្រូវថែបងឯង តើយ៉ាងដូចម្ដេច? ។

– សូមទ្រង់ព្រះមេត្តាប្រោស! ឲ្យគេលាងទូលព្រះបង្គំរាល់ព្រឹក នឹងទឹកថ្លាមុនថ្ងៃរះ ឲ្យគេប្រទានបបរលាយទឹកដោះរាល់ព្រឹកដល់ទូលព្រះបង្គំបរិភោគ នឹងកំទេចធ្យូងមួយស្លាបព្រារាល់ថ្ងៃផង ។

– បើខ្ញុំដឹងប្រាកដថាបងមានោម័យឯងនឹងអាចជួយខ្ញុំក្នុងកិច្ចការនេះបាន នោះខ្ញុំក៏មានបំណងចង់ថែដូចបងនិយាយប្រាប់ដែរ ។

សេះឆ្លើយថា: បពិត្រព្រះនាងជាម្ចាស់! សូមទ្រង់ពិសោធមើល នោះទ្រង់នឹងមិនស្ដាយក្រោយឡើយ ។

នាងពៅខំថែទាំយកចិត្តទុកដាក់ តាមរបៀបដែលសេះប្រាប់ ។ លុះដល់ថ្ងៃទី ១០ សេះនោះគ្រញែងខ្លួន ដំឡើងកេសរ មានកាយធាត់ធំ ហើយរហ័សដូចទន្សាយ ។

បពិត្រព្រះនាងសំឡាញ់! សូមព្រះជាម្ចាស់ញុំាងបុណ្យនិងជ័យជំនះឲ្យសម្រេចដល់ទ្រង់ជាកុំខាន ព្រោះទ្រង់បានថែទាំទូលព្រះបង្គំនឹងអនុញ្ញាតឲ្យទូលព្រះបង្គំបំពេញកិច្ចនៃទូលព្រះបង្គំម្ដងទៀតក្នុងលោក,

ហេតុដូច្នេះ សូមទ្រង់ប្រាប់មកចុះ តើឥឡូវនេះទ្រង់មានរវល់អ្វី ? ទូលព្រះបង្គំត្រូវធ្វើអ្វី ? ។

— ខ្ញុំត្រូវការចង់ទៅនៅបំរើព្រះចៅរាជាធិរាជ ជាចៅហ្វាយនាយ និង ត្រូវការគេទីប្រឹក្សា ព្រមទាំងមគ្គុទ្ទេសក៍ ។ តើបណ្ដានាម៉ឺនតូចធំទាំងអស់ ខ្ញុំត្រូវរើសយកអ្នកណា ? ។

សេះឆ្លើយថា: បើទ្រង់ស្ដេចយាងទៅជាមួយនឹងទូលព្រះបង្គំ សូមទ្រង់កុំព្រួយបារម្ភអ្វីឡើយ មិនបាច់ចាំរកអ្នកណាទៀតទេ ។ ទូលព្រះបង្គំនឹងបំរើទ្រង់ដូចកាលដែលទូលព្រះបង្គំបំរើព្រះវរបិតាដែរ ។ កិច្ចដែលសំខាន់គឺត្រូវព្រះនាងតោងតែស្ដាប់ទូលព្រះបង្គំប៉ុណ្ណោះជាការស្រេច ។

នាងពៅក៏ចាប់ប្រដាប់អីវ៉ាន់ក្ខាម ដើម្បីនឹងធ្វើដំណើរ ។ ព្រះនាងទ្រង់ព្រះពស្ត្រយ៉ាងស្អាត តែកិច្ចតាក់តែងលំអកាយយ៉ាងកណ្ដាល នាងយាងទៅកាន់សំណាក់ព្រះវរបិតា ហើយសូមថ្វាយបង្គំលាថា: បពិត្រព្រះរាជបិតា ! សូមព្រះជាម្ចាស់ជួយរក្សានូវព្រះអង្គ និង សូមឲ្យផ្ដល់នូវសេចក្ដីសុខកាយសប្បាយព្រះហឫទ័យដល់ទ្រង់ជានិរន្តរ៍ ។

— ម្នាលកូនស្រីសំឡាញ់ព្រះបិតា ! សូមឲ្យដំណើរនៃនាងជាសុខ ប៉ុន្តែប្រយ័ត្នកុំភ្លេចបណ្ដាំបិតា ។ បើមានគ្រោះថ្នាក់អ្វីមកដល់ ត្រូវកូនស្រីនឹកដល់ព្រះជាម្ចាស់ ព្រោះសេចក្ដីល្អនិងជំនួយទាំងប៉ុន្មានកើតឡើងតែពីព្រះអង្គ ។ នាងពៅទទួលសេចក្ដីសន្យាទាំងអស់ហើយក៏លាចេញទៅ ។

ព្រះរាជាធ្វើដូចមុនទៀត ។ ព្រះអង្គស្តេចទៅតាមផ្លូវម្ខាងមុននាង ទៅហើយឈប់ចាំនាងត្រង់ស្ពានដែកដដែល ។ ប៉ុន្តែកំពុងធ្វើដំណើរ, សេះបាននិយាយប្រាប់នាង អំពីកលល្បិចដែលព្រះរាជបិតាបំរុងនឹងពិសោធន៍ល្បងចំពោះសេចក្តីក្លាហាននៃនាង តើព្រះនាងអាចដោះខ្លួនរួចឬពុំរួច តើព្រះនាងអាចនឹងទាញយកកេរ្តិ៍ឈ្មោះបានឬទេ ? ។ លុះបានដល់ស្ពាន ចចកស្ទុះមករកនាង ចចកនុះសម្បើមណាស់គួរស្ញែង ភ្នែកដំត្រឡប់លៀនថ្ងៃ មាត់ហាចង្គ្រង អណ្តាតក្រហមឆៅដូចភ្លើង ចង្កូមសស្បាច ហើយស្រែកគំហកដាក់ ។ តាមទំនងចចកនេះដូចអត់អាហារមួយថ្ងៃរួចមកហើយ ។ ប៉ុន្តែ ខណៈដែលចចកស្ទុះចំព្រាវមករកនាងទៅទាំងក្រចកយ៉ាងមុតនោះ ព្រះរាជធីតាគោះសេះឲ្យលោតវៃចចកនឹងដាវនៅដៃ, ហើយបើកុំតែចចកបើកផ្លូវឲ្យ សមរាមានខ្លួនដាច់ជាកំណាត់មិនខាន ព្រោះនាងបានថ្វាយសេចក្តីទុកចិត្តទៅព្រះជាម្ចាស់ស្រេចអស់រលីង នាងមិនធ្វើលេងទេ ទោះបីម្តេចម្តាត្រូវតែញុំាងកិច្ចបំណងឲ្យសម្រេច ។

ព្រះរាជធីតាឆ្លងស្ពានរួចយ៉ាងសង្ហាឥតកោតញញើត ដូចបុរសអាជានេយ្យ ។ ព្រះរាជាតាំងព្រះហ្ឫទ័យក្លាហានជាថ្មី រត់តាមផ្លូវម្ខាងចាំស្កាត់នាងពីខាងមុខទៀត ។ ព្រះរាជានិម្មិតស្ពានប្រាក់ ហើយតំណែងព្រះកាយជាសិង្ហ នៅចាំនាងត្រង់ទីនោះ ។

សេះបានប្រាប់នាងពៅហើយជាស្រេច អំពីឧបសគ្គដែលនាងត្រូវជួបប្រទះនឹងឧបាយដែលនាងត្រូវដោះខ្លួនឲ្យរួច ដើម្បីធ្វើខ្លួនឲ្យបានដល់ទីបំផុតបែបណា ។

លុះបានដល់ស្ពានប្រាក់ សត្វសិង្ហលេចក្លែតឡើង ក្រចកដូចកណ្ដៀវ មាត់ហាយ៉ាងធំបំរុងលេបទាំងសេះទាំងអ្នកជិះ ចង្កូមប្រឆាំងវែងដូចភ្លុកដំរី ។ ព្រៃព្រឹក្សាចំការស្រែសឹងរំភើបញាប់ញ័រដោយសំរែកសត្វសិង្ហទាំងអស់ ។ ក្បាលវាគួរស្ញែងប្រកបដោយកេសរបះឡើងក្រញាងស៊ុបទ្រុបអាចធ្វើឲ្យគូសត្រូវភ័យស្លុតស្ទើរបាត់ស្មារតី ។ ប៉ុន្តែនាងពៅមានសេះជាអ្នកបញ្ជោរចិត្តលើកដាវគ្រវីវ៉ៃសិង្ហឥតរួញរា បើប្រសិនជាកុំតែវារត់ចូលជ្រកក្រោមស្ពានទាន់ កុំអីវាមុខជាមានកាយដាច់ជាពីរបីកំណាត់មិនខាន ។ ខណៈនោះ នាងធ្លងស្ពានប្រាក់ហួសទៅ សូមអរគុណចំពោះព្រះជាម្ចាស់ ហើយនឹកក្នុងចិត្តថាមិនដឹងជាមានអ្វីនៅចាំយាយីខាងមុខទៀតទេ ។

នាងពៅដែលតាំងពីប្រសូតមក មិនដែលចេញពីវាំងប្រាសាទសោះ ស្រាប់តែស្រឡាំងកាំងនឹងឥដ្ឋារម្មណ៍នៃធម្មជាតិ ដែលមាននៅពាសពេញទាំងវាល ។ ជួនកាលព្រះរាជធីតាក្នុកព្រះហ្ឫទ័យបង់ចុះពីសេះទៅប្រលេះបុប្ផាផ្សេងៗ យកមកធ្វើជាផ្ទួងប្រដាប់កាយ ព្រោះរត្នដែលនាងបានទតឃើញក្នុងទីនេះ គឺសុទ្ធតែផ្កាទាំងអស់, ជួនកាលព្រះនាងចង់ឈប់

សម្រាកព្រះកាយក្រោមម្លប់ឈើ ដើម្បីនឹងទ្រង់ព្រះសណ្ដាប់នូវសំឡេងនៃបក្សីយំពីពេលព្រឹក បើអ្នកណាបានស្ដាប់មុខជានឹងដេកលក់មួយរំពេច, ជួនកាលនាងចង់ទៅរកជ្រោះ ដែលមានទឹកថ្លាត្រជាក់ដូចកញ្ចក់ ហើយហូរចេញមកពីថ្មចង្អែះភ្នំ ; ព្រះនាងសព្វព្រះហឫទ័យទតព្រះនេត្រមើលទឹកហូរពេនចុះពេនឡើងដូចពស់វារ ទីង ទ្រង់ព្រះសណ្ដាប់នូវស្នូរដែលវាបន្លឺឡើងនូវសភាពស្មោះទាំងឡាយ ។ ប៉ុន្តែសេះពុំព្រមឲ្យព្រះនាងឈប់ ចេះតែបន្តឲ្យព្រះនាងប្រញាប់ទៅមុខទៀត ហើយនិយាយប្រាប់ថា ព្រះរាជបិតានឹងនៅធ្វើការពិសោធន៍មួងទៀត ។ សេះបានពន្យល់ប្រាប់ព្រះនាងទៀត អំពីទំនងដែលនាងត្រូវធ្វើដើម្បីឲ្យបានជួងផុតនូវឧបសគ្គនោះ ។

នាងពៅទទួលស្ដាប់ដំបូន្មានសេះទាំងអស់ ហើយសព្វព្រះហឫទ័យធ្វើតាមគ្មានខ្វះកន្លែងណា ព្រោះនាងបានសង្កេតទៅឃើញថា សុទ្ធតែបានសេចក្ដីចំរើនទាំងអស់ ។

ព្រះរាជាស្ដេះទៅពីខាងមុខជាថ្មីទៀត ទ្រង់និម្មិតស្ពានមាស ក្រឡាព្រះកាយជានាគរាជក្បាលដប់ពីរ ហើយពួននៅក្រោមស្ពានរង់ចាំនាង ។ កាលដែលនាងពៅមានបំណងចង់ឆ្លងស្ពាន នាគស្ដេះឡើងរាំងផ្លូវទាំងក្អកក្អួរខ្លាច ហើយយកកន្ទុយគ្រវីទៅមក ព្រួសភ្លើងចេញតាមមាត់ អណ្ដាតក្រហមឆេះស្រុះដូចព្រួញ ។ នាងពៅតក់ស្លុតស្ទើរបាត់ស្មារតីព្រឹព្រះ

សិរសាព្រះកេសាឡើងក្រញាង ។ សេះលុះឃើញព្រះនាងបាត់សតិដូច្នោះ ក៏រំលឹកព្រះនាងឡើងវិញ ហើយប្រាប់នូវកិច្ចដែលត្រូវធ្វើ ។ ព្រះរាជធីតាដឹងខ្លួនឡើងវិញក៏ញាក់សេះភ្លាម កាន់បង្ហៀរយ៉ាងខ្ជាប់ដោយដៃខាងឆ្វេង ដៃស្តាំកាន់ដាវបំផាយសេះដាក់នាគ ។

ការតយុទ្ធគ្នាតាំងនៅអស់មួយម៉ោង ។ សេះនាំនាងពៅស្ទុះទៅខាងចម្ហៀងជានិច្ច ដើម្បីឲ្យនាងពៅមានឱកាសអាចកាប់ក្បាលនាគបាន ប៉ុន្តែបច្ចាមិត្រក៏ឆ្លាតប្រសប់ការពារខ្លួនណាស់ដែរ ។ លុះទីបំផុត នាងពៅសម្រេចផ្ចាញ់នាគបាន ដោយធ្វើឲ្យនាគត្រូវរបួសពីរបីកន្លែង នាគរាជក៏ក្លាយខ្លួនជាមនុស្សវិញ ។

នាងពៅឃើញព្រះរាជានៅពីមុខ ហើយមិនសុខចិត្តជឿថាជាព្រះរាជបិតាមែន ។ ប៉ុន្តែព្រះរាជាចាប់នាងឱបថើបត្រង់ថ្ពាសហើយមានព្រះរាជឱង្ការថា :

បិតាពិនិត្យទៅឃើញថា កូនឯងពិតជាស្រីក្លាហានមែនហើយ, កូនឯងបេះរើសយកសេះនេះមក បើកុំដូច្នោះ កូនឯងទៀងតែត្រឡប់ទៅវាំងវិញដូចជាបង ៗ ឯទៀតមិនខាន ។ បិតាមានសេចក្តីសង្ឃឹមទុកជាស្រេច ថាកូនស្រីនឹងញុំាងករណីយកិច្ច ដែលកូនត្រូវធ្វើដោយចិត្តស្ម័គ្របានសម្រេចដល់ទីបំផុត ។ ហើយចូរកូនកុំភ្លេចបណ្តាំបិតាឲ្យសោះ ទាំងចូរធ្វើតាមសេះកុំបីឃ្លាយឡើយ ។ បើធ្វើដូច្នោះហើយ យើងនឹងបានជួបគ្នាវិញជាប្រាកដ ។

នាងពៅក្រាបបង្គំទូលស្នងព្រះឱង្ការវិញថា: បពិត្រព្រះរាជបិតា ! សូមព្រះជាម្ចាស់ស្ដាប់ពាក្យព្រះអង្គចុះ ហើយសូមឲ្យព្រះរក្សាទ្រង់ឲ្យប្រកបដោយសេចក្ដីសុខតរៀងទៅ ៗ នាងចាប់ព្រះហស្ដព្រះរាជបុត្រ (ថើប) ហើយជនទាំងពីរក៏បែកគ្នាទៅ ៗ

ខាងក្រោយការធ្វើដំណើរយ៉ាងយូរ នាងពៅបានដល់គីរីបពិតទាំងឡាយដ៏ខ្ពស់ ៗ ហើយទ្រង់ទតឃើញយក្សពីរកំពុងតែច្បាំងគ្នានៅកន្លែងនោះ ៗ យក្សទាំងពីរនេះច្បាំងគ្នា ៩ ឆ្នាំហើយ តែនៅមិនទាន់ដឹងចាញ់ឈ្នះនៅឡើយ គឺជាការតយុទ្ធស្លាប់រស់ ៗ លុះអសុរីទាំងពីរក្រឡេកឃើញព្រះនាងកាលណា ក៏បានសន្និដ្ឋានថា ព្រះនាងជាយុវជនខ្លាំងពូកែ; រូបអាមួយស្រែកអង្វរថា បពិត្រព្រះអង្គម្ចាស់! បពិត្រព្រះអង្គម្ចាស់! សូមព្រះអង្គអាណិតជួយច្បាំងទូលព្រះបង្គំ; លុះកិច្ចនេះសម្រេចហើយ ទូលព្រះបង្គំនឹងបំរើទ្រង់វិញជាមិនខាន ៗ យក្សមួយទៀតស្រែកអង្វរថា: បពិត្រព្រះអង្គម្ចាស់! សូមទ្រង់ជួយទូលព្រះបង្គំវិញ, លុះបានឈ្នះហើយ ទូលព្រះបង្គំនឹងថ្វាយសេះមួយយ៉ាងជំនាញឈ្មោះសុរ្យាបកា ៗ

នាងពៅសួរសេះថា: យើងត្រូវជួយយក្សណាល្អ? ៗ សេះទូលថា: ត្រូវជួយយក្សមួយដែលសន្យានឹងថ្វាយសេះឈ្មោះសុរ្យាបកា ៗ សេះនោះមានវិជ្ជានុភាពជាងទូលព្រះបង្គំខ្លាំងណាស់ ព្រោះវាត្រូវជាប្អូន

ទូលព្រះបង្គំ ។ ព្រះរាជធីតាបរសេះបំផាយសំរុកចូលទៅកាប់យក្សតែមួយដាវ យក្សនោះដាច់ខ្លួនជាពីរបីកំណាត់ ស្លាប់មួយរំពេច ។

យក្សមួយដែលរួចពីគ្រោះកាច ស្ទុះមកឱបបាទព្រះនាង ហើយសូមអរព្រះគុណ ។ រួចក៏នាំព្រះនាងទៅដើម្បីនឹងថ្វាយនូវសេះឈ្មោះសុព្យាបកាតាមពាក្យសន្យា ។ អ្នកទាំងអស់គ្នាក៏បានទៅដល់វាំងយក្ស ។ ម្តាយយក្សដែលឃើញកូនរួចរស់ជីវិត ក៏មានសេចក្តីត្រេកអររកអ្វីប្រៀបគ្មាន ហើយសំដែងសេចក្តីអរគុណជាអនេកប្បការ ចំពោះព្រះអង្គម្ចាស់ហាវហានដែលបានស្រង់ជីវិតកូននៃអាត្មា ។

ព្រះរាជធីតាសុំកន្ទេលឈប់សម្រាកព្រះកាយបន្តិច ព្រោះនឿយហត់អស់កំលាំងដោយធ្វើដំណើរផ្លូវឆ្ងាយ ។ គេក៏ថ្វាយបន្ទប់មួយដ៏សមគួរដល់ព្រះនាង ហើយទុកព្រះនាងឲ្យនៅផ្ទំតែឯកឯង ។ ខណៈនោះព្រះនាងធ្វើកលជាមើលថែសេះសិន ព្រះនាងលួចសួរសេះថា: តើនឹងមានគ្រោះថ្នាក់អ្វីដល់ព្រះនាងដែរឬទេ? ។ សេះក៏បានខ្សឹបប្រាប់សព្វគ្រប់នូវឧបាយកលផ្សេងៗ ដែលត្រូវធ្វើ ។

នាងយក្ខិនីម្តាយយក្សមានសេចក្តីពិតាល់ពេក ហើយនិយាយប្រាប់កូនថា: ព្រះអង្គម្ចាស់ហាវហានដែលជួយស្រង់ជីវិតកូនឯង ប្រហែលជាស្ត្រីទេ ហើយស្ត្រីដែលមានរិទ្ធិដូច្នេះល្អយកធ្វើជាប្រពន្ធណាស់ ។ ប៉ុន្តែកូនគាត់ឆ្លើយថា: ក្នុងលោកនេះមិនមានស្ត្រីណាអាចកាន់ព្រះខ័ន

ចូលចប្រាំងយ៉ាងអន់អាចដូចជាបុរសជាតិឡើយ ៗ នាងយក្ខិនីចង់ធ្វើសេចក្ដីសង្ស័យឲ្យលេចចេញប្រាកដឡើង ៗ ពេលរាត្រី នាងយក្ខិនីយកផ្កាទៅលួចដោតនៅនាក្បាលដំណេកកូនរបស់ខ្លួនទាំងនាងពៅ ព្រោះថាបើផ្កានោះស្វិតគឺជាគូអង្គបុរស បើផ្កានៅស្រស់ជាគូអង្គស្ត្រី ៗ

ព្រះរាជធីតាតាមដំបូន្មានរបស់សេះ ទ្រង់តើនឡើងពេលមុនថ្ងៃរះ គឺជាវេលាដែលគេពល់គ្នាកំពុងដេកស្រួល ក៏ទ្រង់យាងដោយចំអើតព្រះបាទយ៉ាងសន្សឹមៗ ហើយទ្រង់ចូលក្នុងបន្ទប់យក្ស យកផ្កាដែលដោតនៅឯក្បាលព្រះក្រឡាបន្ទំរបស់ព្រះនាង ទៅដោតឯក្បាលដំណេកយក្ស យកផ្កាឯក្បាលដំណេកយក្សមកដោតទុកឯក្បាលក្រឡាព្រះបន្ទំរបស់ព្រះអង្គវិញ រួចព្រះនាងទ្រង់ត្រឡប់ផ្ទំទៅវិញយ៉ាងស្រួល ៗ

លុះព្រឹកឡើងនាងយក្ខិនីភ្ញាក់ពីព្រលឹម ក្រោកស្ទុះរត់ទៅមើលផ្កាដែលនៅឯក្បាលដំណេកកូនរបស់ខ្លួនឃើញស្វិត រួចរត់ទៅមើលផ្កាដែលនៅឯក្បាលក្រឡាព្រះបន្ទំនៃព្រះរាជធីតាក៏ឃើញស្វិតដូចគ្នា ៗ នាងយក្ខិនីកង្វល់ពេក ប៉ុន្តែគាត់នៅតែមិនទាន់អស់ចិត្ត ហើយប្រាប់កូនថា: ប្រាកដជាមិនមែនប្រុស, អញស្ដាប់សំដីដែលនិយាយមើលពងវែបហ្នឹង មើលទៅសក់ធ្លាក់សំយាកមកលើស្មា គន់មើលទៅលំអនៃទឹកមុខ ទឹងភ្នែកចំព្រែឡោតបែបរហ័ស ដៃគូបជើងធ្មារដូចស្រីទេពអប្សរ គឺជាស្ត្រីប្រាកដ ប៉ុន្តែដែលឯងមើលពុំយល់ដោយសារនាងទ្រង់ប្រដាប់ចម្បាំងប៉ុណ្ណោះ ៗ តមក ជនទាំងពីរគិតធ្វើការពិសោធន៍មួងទៀត ៗ

ខាងក្រោយដែលគេជូនអរុណសួស្តីដល់គ្នានឹងគ្នាតាមទំនៀមហើយ, កូនយក្សនាំនាងពៅទៅលេងក្នុងសួនច្បារ ។ រាប់បង្ហាញផ្កាផ្សេងៗដល់ព្រះនាង ព្រមទាំងអញ្ជើញព្រះនាងឲ្យបេះទ្រង់នឹងថើបលេងកំសាន្ត ព្រោះសុទ្ធតែជាផ្កាមានក្លិនក្រអូប ។ ប៉ុន្តែព្រះនាងនឹកដល់បណ្តាំសេះ ក៏ទ្រង់សួរទៅយក្សវិញថា: ចុះហេតុអ្វីក៏នាំយើងមកកាន់សួនច្បារតាំងពីព្រលឹមអីម្ល៉េះ ដើម្បីរមិលមើលផ្កាដូចជាស្រី ព្រោះកិច្ចជាប្រថមគឺត្រូវយើងទៅមើលសេះឯក្រោល តើវាសុខសប្បាយទេឬដូចម្តេច? ។

កូនយក្សយកពត៌មាននេះមកប្រាប់ម្តាយ ប៉ុន្តែនាងយក្ខិនីនៅតែមិនព្រមចុះចាញ់ ហើយនាងម្តាយសម្រេចកូនឲ្យលការពិសោធន៍ជាទីបំផុតមួយទៀតមើល ។ គឺថាត្រូវនាំព្រះអង្គម្ចាស់ទៅក្នុងបន្ទប់ដែលដាក់ទុកសុទ្ធតែគ្រឿងអាវុធ ហើយសូមឲ្យព្រះអង្គម្ចាស់ជ្រើសរើសយកអាវុធណាមួយ, ប្រសិនបើការជ្រើសរើសនេះធ្លាក់ទៅលើអាវុធណាដែលលំអដោយគ្រឿងពេជ្រ-មាសនោះ កុំបាច់សង្ស័យ គឺប្រាកដជាការរើសនៃស្ត្រី ។

ខាងកត្តកិច្ច កូនយក្សនាំព្រះអង្គម្ចាស់ហាវហានទៅក្នុងបន្ទប់ដាក់អាវុធទាំងឡាយ ។ ក្នុងទីនោះ មានអាវុធដាក់ជម្រៀបជាជួរគ្រប់បែបគ្រប់យ៉ាង ខ្លះជាអាវុធលាតសាម័ញ្ញ ខ្លះជាអាវុធប្រដាប់ដោយគ្រឿងត្បូងពេជ្រដាំជាលំអ ។

(មានត)

## សព្ទបារាំងប្រែជាខ្មែរ

របស់

គណៈកម្មការវប្បធម៌

# ពុទ្ធសាសនបណ្ឌិត្យ ជ្រើស

---

## សូមកែតាម

សព្ទបារាំងប្រែជាខ្មែរ ដែលមានចុះផ្សាយក្នុងកម្ពុជសុរិយា ឆ្នាំ ១៩៤៩-៥០, មានសព្ទខ្លះក្រុមជំនុំវប្បធម៌ត្រូវកែប្រែជាថ្មី សព្ទខ្លះបោះពុម្ពខុសក្លាត់ ៗ ដើម្បីទុកជាច្បាប់ត្រឹមត្រូវ ទាំងជាប្រយោជន៍ដល់ផ្លូវសិក្សាតទៅ សូមកែតាមដូចតទៅនេះ :

### កម្ពុជសុរិយា

## លេខ ៧ ខែកក្កដា ឆ្នាំ ១៩៤៩

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| Conseil d état | Conseil d'Etat | ៥០៩ | ១២ |
| ក្រសួងរដ្ឋមន្ត្រី | ក្រសួង | ៥១០ | ១ |
| Chef- de Serdice | Chef de Service | ៥១០ | ៦ |
| Chef de Bueau | Chef de Bureau | ៥១០ | ៨ |
| អក្ខរាវិរុទ្ធនៃពាក្យ | អក្ខរាវិរុទ្ធនៃពាក្យ | ៥១២ | ១០ |

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
| --- | --- | --- | --- |
| ១៧-៤-៤៩ | ១៧-២-៤៩ | ៥១២ | ១៣ |
| Fanatiste | Fanatique | ៥១៣ | ៧ |
| សន្ធិសិទ្ធិ | សន្ធិសិទ | ៥១៤ | ៥ |
| សុខុមប្រាណ | អតិសុខុមប្រាណ | ៥១៤ | ១១ |
| សុខុមទស្សន៍ | អតិសុខុមទស្សន៍ | ៥១៤ | ១២ |

## លេខ ៨ ខែសីហា ឆ្នាំ ១៩៤៩

| | | | |
| --- | --- | --- | --- |
| កងបលនះ | កងបល័ន | ៥៨២ | ១០ |
| បិត្តទឹងដឹង | បិត្តទឹងជឹង | ៥៨២ | ១៦ |
| អគ្គពិនិត្យនៃជាតិ | អគ្គពិនិត្យនៃប្រជាជាតិ | ៥៨៣ | ២ |
| អនុសេនីយ | អនុសេនីយត្រី | ៥៨៤ | ១០ |
| Séconde maître | Second maître | ៥៨៦ | ១ |
| វរសេនាឯក | វរនាវីឯក | ៥៨៦ | ១៣ |
| វរសេនាទោ | វរនាវីទោ | ៥៨៦ | ១៤ |
| វរសេនាត្រី | វរនាវីត្រី | ៥៨៦ | ១៥ |
| Le feu ការបាញ់ | Feu ! បាញ់ ! | ៥៨៨ | ៣ |
| Compagne | Campagne | ៥៨៨ | ៤ |
| បាំឆ្នក់ | ពួនបាំឆ្នក់ | ៥៨៨ | ៨ |

## លេខ ៩ ខែកញ្ញា ឆ្នាំ ១៩៤៩

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| អ្នកកាន់កាប់ការ | អ្នកកាន់កាប់ការ-បណ្ណាធិការ | ៦៧៦ | ៣ |
| Camarad | Camarade | ៦៨០ | ៨ |
| Sympathi | Sympathie | ៦៨១ | ១ |
| ការពិសាធន៍ | ការពិសោធន៍ | ៦៨១ | ៤ |
| បរិមាត្រា | បរិមាត្រ | ៦៨១ | ៧ |
| វិជ្ជមាត្រា | វិជ្ជមាត្រ | ៦៨១ | ៨ |

## លេខ ១០ ខែតុលា ឆ្នាំ ១៩៤៩

| | | | |
|---|---|---|---|
| autipathic | autipathie | ៧៣៥ | ៧ |
| អធិការនាយករងបឋម-សិក្សា | អធិការរងបឋមសិក្សា | ៧៣៥ | ១១ |
| គ្រូបង្ហាត់សាលាទិកនិក | គ្រូបង្ហាត់សាលាតិកនិក | ៧៣៦ | ៣ |
| សមភាព | សមភាគ | ៧៣៨ | ៧ |
| សមភាគ | វិសមភាគ | ៧៣៨ | ៨ |
| Distincion honorifique | Distinction houorifique | ៧៤២ | ៤ |

## លេខ ១១ ខែវិច្ឆិកា ឆ្នាំ ១៩៤៩

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ការប្រគល់វិញ្ញាបនប័ត្រ បានប្រើអស់ហើយ | ការប្រគល់វិញ្ញាបនប័ត្រ ដែលប្រើអស់ហើយ | ៨២៨ | ២ |
| Le S. E. C. I. R. Certifie que l'Opération ne donne bien . . . . . . . . . . . . . | Le S. E. C. I. R. certifie que l'opération ne donne pas droit. . . . . . . . . . | ៨២៨ | ១២ |
| Cette prorogation devra Obligatoirement être demandée deux Semaines un moins . . . . . . . . . . . Port ou Bureau duonier | Cette prorogation devra obligatoirement âtre demandée deux semaines au moins . . . . . . . . . Port ou Bureau Douanier | ៨២៩ | ៨ |
| វិជ្ជាឋាន: | វិជ្ជាឋាន | ៨៣០ | ១៣ |
| កណ្ណពេគ | កណ្ឋពេគ | ៨៣១ | ៧ |

## លេខ ១២ ខែធ្នូ ឆ្នាំ ១៩៤៩

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| merveilleux | Le merveilleux | ៩០៧ | ៥ |
| Est autorisé ouvrir à | Est autorisé à ouvrir à | ៩១២ | ៣ |
| (. . . មានបទបញ្ញត្តិ កន្ធិបំពូក ៨ | អ្នកទទួលអនុញ្ញាតត្រូវ ប្រតិបត្តិតាម. . . ចំពោះ បទបញ្ញត្តិកន្ធិបំពូក ៨. . . | ៩១២ | ៨ |

# កម្ពុជសុរិយា

## លេខ ២ ខែកុម្ភៈ ឆ្នាំ ១៩៥០

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| Vendredi 17-9 49 | Vendredi 17-9-48 | ៦៦ | ៤ |
| ប្រាជ្ញ | ប្រាជ្ញ, បណ្ឌិត | ៨៥ | ១៥ |
| ប្រាជ្ញា | ប្រាជ្ញា, គតិបណ្ឌិត | ៨៥ | ១៦ |
| Service de la flotte | Service de la Flottille | ៨៦ | ១៤ |
| ត. វេជ្ជបណ្ឌិត | ត. វេជ្ជបណ្ឌិតា | ៨៧ | ៣ |
| បានប្រោសប្រទាន | យើង .......... បានប្រោសព្រះរាជទាន | ៨៩ | ១៤ |
| Direction des Atelliers de la flotte | Direction des Ateliers de la Flottille | ៩១ | ១០ |
| Identification | Identificateur | ៩៤ | ១៣ |
| អធិការគង្គា និងរុក្ខា | អភិបាលគង្គា និងរុក្ខា | ៩៣ | ៧ |
| Inspecteur des Eaux et Forêts (mot ajouté) | អធិការគង្គា និងរុក្ខា (ពាក្យថែម) | ៩៣ | ៧ |

## លេខ ៥ ខែឧសភា ឆ្នាំ ១៩៥០

| | | | |
|---|---|---|---|
| ប្រក្រតិទិន | ប្រតិទិន | ៣២៩ | ១៥ |

## លេខ ៦ ខែមិថុនា ឆ្នាំ ១៩៥០

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| លទ្ធិសុទិដ្ឋិ | លទ្ធិសុទិដ្ឋិនិយម | ៤១២ | ១៣ |
| បេទ្ធិទុទិដ្ឋិ | លទ្ធិទុទិដ្ឋិនិយម | ៤១២ | ១៤ |
| អ្នកសុទិដ្ឋិ | អ្នកសុទិដ្ឋិនិយម | ៤១៣ | ៣ |
| អ្នកទុទិដ្ឋិ | អ្នកទុទិដ្ឋិនិយម | ៤១៣ | ៤ |
| អ្នកកត់កិនសត្វ | កត់កិនសត្វ | ៤១៣ | ១៨ |
| traqueur | trayeur | ៤១៦ | ២ |

## លេខ ៨ ខែសីហា ឆ្នាំ ១៩៥០

| | | | |
|---|---|---|---|
| Amlassadeur | Ambassadeur | ៥៨១ | ១៦ |

## លេខ ៩ ខែកញ្ញា ឆ្នាំ ១៩៥០

| | | | |
|---|---|---|---|
| ហេតុគហបតី | គហបតី | ៦៦០ | ៣ |

## លេខ ១០ ខែតុលា ឆ្នាំ ១៩៥០

| | | | |
|---|---|---|---|
| | ១៦-៩-៤៩ | ៧៣១ | ៦ |
| អត្តាចិនភាព | អត្តាធិនភាព | ៧៣១ | ៧ |
| សេចក្ដីស្ដាយ... មវៃម | សេចក្ដីស្ដាយក្រោយ | | |
| ក្រោយ | " មវៃម | ៧៣២ | ៦ |

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ឈុទ | ឈុត | ៧៣២ | ១២ |
| Immigrtion ក្រុមត្រួត | Immigration ក្រុម | | |
| ត្រាជនចូលស្រុក | អន្តោប្រវេសន៍ | ៧៣៥ | ១០ |

## លេខ ១១ ខែវិច្ឆិកា ឆ្នាំ ១៩៥០

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ផែនដី | ដែនដី | ៨២៥ | ៦ |
| ពាណិជ្ជកម្ម | បទពាណិជ្ជកម្ម | ៨២៦ | ៥ |
| អាជ្ញា | បទអាជ្ញា | ៨២៦ | ៦ |
| សង្គបិកសមាជិក | សង្គមិកសមាជិក | ៨២៦ | ៩ |
| La légion étrangérs | La Légion Etrangère | | |
| កងសារបរទេស | កងអាសាបរទេស | ៨២៨ | ៤ |
| hamonie | harmonie | ៨២៨ | ១៤ |

## លេខ ១២ ខែធ្នូ ឆ្នាំ ១៩៥០

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ផ្ចិតផ្ចង់ | សិស្សផ្ចិតផ្ចង់ | ៩០២ | ២ |
| យកចិត្តទុកដាក់ | សិស្សយកចិត្តទុកដាក់ | ៩០២ | ៣ |
| Rasemblement | Rassemblement | ៩០២ | ១០ |
| បញ្ជាការសេន្យានុភាព | បញ្ញាការសែន្យានុភាព | ៩០២ | ១៨ |
| គ្រួប្រឹងប្រៀន | គ្រូប្រឹតប្រៀន | ៩០៤ | ១ |

រឿងសាមកុក

កណ្ឌទី ៩

# ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តទៅ)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ទៀវពី កួនអ៊ូ នឹងតៀវហ៊ុយនាំទាហាន ៣ ពាន់ប្លាយ ជាទ័ពមុខ ស្រូតរូតទៅដល់ស្រុកឈីជីវ ៗ ចំណែកប៉ិតុកចូលទៅដល់ក្រុងឈីជីវទើប យកសេចក្ដីទៅជំរាបតូកៀមថា ខុងយ៉ុងបានបបួលទៀវពីឲ្យលើកទ័ពមក ជួយលោក ខុងយ៉ុងនឹងទៀវពីនោះនឹងលើកទាហានតាមមកជាក្រោយ ៗ

ឯតាន់តេងដែលទៅសុំកងទ័ពតេងកៃនោះ ក៏ត្រឡប់មកប្រាប់ តូកៀមថា តេងកៃនឹងលើកមកជួយ ៗ តូកៀមបានឮដូច្នោះ ក៏បាន ធូរស្បើយក្នុងចិត្ត ។ ឯខុងយ៉ុងចៅហ្វាយស្រុកប៉ាក់ហៃ នឹងតេងកៃចៅ ហ្វាយស្រុកឈៀងជីវ ក៏នាំទាហានលើកទៅដល់ស្រុកឈីជីវ ឃើញ

កងទ័ពបូឆូតាំងកាយប្រកិតជិតជាប់គ្នា ៗ ខុងយ៉ុងទឹងតេងកៃក៏ឲ្យតាំងបន្ទាយពុំក្រោយទ័ពបូឆូទាំង ២ បែក ប៉ងទឹងមើលគលសឹក ៗ បូឆូឃើញដូច្នោះគិតថា "ឥឡូវមានកងទ័ពមកតាំងនៅពីក្រោយជា ២ បែក បើទឹងលើកវាយបំបែកទៅមុខ ក្រែងពីក្រោយលើកគំហុកខ្ទប់មកទៀត" គិតហើយក៏បែងទាហានឲ្យមានពួក បែរទៅមុខផងបែរមកក្រោយផងទាំងសងខាង ៗ

កាលឡេពីលើកទាហានទៅដល់ស្រុកឈើដីវហើយ ឃើញកងទ័ពខុងយ៉ុងទឹងតេងកៃ តាំងបន្ទាយកាយប្រកិតគ្នានឹងទ័ពបូឆូជា ២ បែក ដូច្នោះ ក៏ចូលទៅជួបនឹងខុងយ៉ុងៗ មានអំណរណាស់ និយាយនឹងឡេពីថា បូឆូលើកទាហានមកធ្វើសង្គ្រាមជាច្រើនហួសប្រមាណ ខ្លួនបូឆូក៏ជាមនុស្សមានសតិបញ្ញាជំនាញស្ទាញស្ទាត់ក្នុងការពិជ័យសង្គ្រាម, ដែលយើងនឹងលើកទាហានចូលកាប់យកដោយឆាប់ទាន់ចិត្តនោះ ឃើញទឹងបង់ការ, ត្រូវតែការង់បង្អង់មើលគលការណ៍សិន បើឃើញបានចំណាប់ហើយ សឹមយើងលើកចូលទៅច្បាំងនឹងបូឆូ ៗ

ឡេពីតបថា ដែលអ្នកនិយាយនោះត្រូវណាស់ តែខ្ញុំក្រែងនឹងតាំងនៅយូរមិនបាន ព្រោះស្បៀងអាហារក្នុងស្រុកឈើដីវតិចពេក ពួកអ្នកស្រុកក៏អត់ឃ្លាន; បើដូច្នេះខ្ញុំឲ្យក្លួនអ៊ូនឹងជូឡុងនាំទាហាន ៤ ពាន់មករួមនឹងអ្នក ឯខ្លួនខ្ញុំនឹងតៀវហ៊ុយនាំទាហានជាង ១ ពាន់ ពារទំលាយកង

ទ័ពចូចូចូលទៅឲ្យដល់ស្រុកឈីជីវតែម្ដង ប្រយោជន៍និងបាននិយាយប្រឹក្សាការនឹងតូកៀម ហើយនឹងប្រមាណមើលស្បៀងអាហារក្នុងស្រុកដែលមាននៅនោះច្រើនប្ដិប និងបានសម្រេចគិតគ្នាតទៅទៀត ។ ខុងយ៉ុងក៏យល់ព្រមផង ។ ខណៈនោះ ឡៅពីនិងតៀវហ៊ុយនាំទាហានចូលទៅដល់មុខបន្ទាយចូចូ ។ ទាហានចូចូឃើញក៏លើកគ្នាមកពាំងពីមុខ ។ កងទ័ពទាំងសងខាងក៏តាំងតែចូលលុកតប្រយុទ្ធគ្នាទៅវិញទៅមក បីដូចរលកក្នុងមហាសមុទ្រ ។

ឯអុីគិមទាហានឯកនោះបរសេះចេញមកមុខទាហាន ហើយស្រែកសួរឡៅពីនិងតៀវហ៊ុយថា ឯងមកនេះនឹងទៅណា? ទាហានឯងផាង ១ ពាន់ប៉ុណ្ណោះ នឹងស្កាំថ្វីដៃទាហានយើងឬ? ។ តៀវហ៊ុយបានឮឈឺចិត្តណាស់ មិនបានឆ្លើយឆ្លងថាដូចម្ដេច បរសេះស្ទុះផ្ចួចទៅប្រយុទ្ធនឹងអុីគិមបាន ១០ ស្ទៀត ។ ឡៅពីកាន់គ្រឹបបរសេះចូលទៅជួយតៀវហ៊ុយពីក្រោយ ។ អុីគិមកម្លាំងខ្សោយក៏ចុយត្រឡប់ តៀវហ៊ុយដេញជាប់កាប់ទាហានចូចូស្លាប់ជាច្រើនណាស់ ។ ឡៅពីនិងតៀវហ៊ុយនាំទាហានទៅដល់មាត់ទ្វារស្រុក ។

ឯតូកៀមឡើងពិនិត្យមើលលើសែនបន្ទាយ ឃើញកងទ័ពដេញគ្នាទំលាយចូលមកដល់មាត់ទ្វារ ក៏ឃើញទង់ជ័យក្រហមជាសំគាល់មានអក្សរជាទង់ថា "ឡៅពីចៅហ្វាយស្រុកផេងឌួនគួន" តូកៀមមានអំណរ

ពន់ប្រមាណ បង្គាប់ឲ្យពាហានស្ទុះទៅបើកទ្វារទទួលឡៅពីចូលទៅក្នុងស្រុក ទើបអញ្ជើញឲ្យអង្គុយហើយរៀបតុលៀងអាហារ ។ ឡៅពីនិងតៀវហ៊ុយនៅអស់ពលសេនា បរិភោគរួចហើយ, ឡៅពីដំរាបគួកៀមថា ដែលយើងចូលមកនេះ បានកាប់ឆ្ការពារទំលាយកងទ័ពបូបវិនាសអស់ជាច្រើន ។ គួកៀមបានស្តាប់ក៏មានសេចក្តីត្រេកអរណាស់ តាំងតែគយគន់មើលរូបរាងឡៅពីឃើញសមគួរជាពូជព្រះរាជវង្ស ទាំងរាហារសំដីដែលចរចាពេះរាយសុភាពរាបសាអ្នកចិត្តល្អ, គួកៀមចាត់ប្រើចិត្តក ឲ្យចូលទៅយកត្រាសម្រាប់ចៅហ្វាយស្រុកឈើដីវចេញមកជាប្រញាប់ ហើយប្រគល់ឲ្យឡៅពី។ ឃើញដូច្នោះ ក៏នឹកភ័យស្រដីតបទៅថា ដែលលោកយកត្រាសម្រាប់ខែត្រមកឲ្យខ្ញុំនេះ ដោយហេតុអ្វីប្រការម្តេច? ។ គួកៀមតបថា សព្វថ្ងៃនេះព្រះចៅហៀនតេបានគ្រងរាជសម្បត្តិ ព្រះជន្មវស្សាក៏ទ្រង់នៅជាព្រះរាជកុមារណាស់ នាហ្មឺនមុខមន្ត្រីដែលគ្មានចិត្តជាសុចរិតទៀងត្រង់នោះ ក៏រមែងធ្វើការជាចលាចលផ្សេងៗ ផែនដីមានតែសេចក្តីក្តៅក្រហាយមកជារឿយៗ ខ្លួនខ្ញុំក៏ចាស់ជរា នឹងធ្វើការបំរុងផែនដីតទៅទៀតពុំបាន ខ្ញុំឃើញថាអ្នកជាពូជព្រះរាជវង្សខ្ពង់ខ្ពស់មានកេរ្តិ៍ឈ្មោះជាអ្នកមានសតិបញ្ញា ហើយមេត្តារាប់អានបណ្តារាស្ត្រទាសករទាំងពួងឲ្យបានសេចក្តីសុខៈក្សេមក្សាន្ត, ខ្ញុំបានតាំងចិត្តគិតជាស្រេច ទើបលើកត្រានេះជូនៈជូនឲ្យលោកទទួលធ្វើជាចៅ-

ឆ្ងាយស្រុកឈើជីវតទៅ ដើម្បីនឹងបានគិតកំចាត់សត្រូវរាជសម្បត្តិឲ្យខ្ចាត់ខ្ចាយចេញ, បើអ្នកពេញចិត្តជាប្រាកដ ខ្ញុំនឹងធ្វើសំបុត្រចូលទៅក្រាបទូលព្រះចៅហៀនគេ សូមឲ្យទ្រង់បានជ្រាប ។

ឡៅពីបានស្តាប់ក៏ឱនគំនាប់គូកៀមហើយថា ខ្លួនខ្ញុំជាពូជព្រះរាជវង្សពិតមែន, តែជាគំនិតនឹងសតិប្បញ្ញាតិចណាស់; តាំងពីចូលធ្វើរាជការមិនទាន់បានគុណគាប់ប្រសើរយ៉ាងណាទេ, សព្វថ្ងៃធ្វើត្រឹមតែចៅហ្វាយស្រុកបត្យា គិតថាចំណោះរបស់ខ្លួនមិនជួននៅឡើយ; ដែលខ្ញុំលើកទាហានមកនេះ ព្រោះចិត្តប្រាថ្នានឹងជួយលោកដែលច្បាំងនឹងចូចូប៉ុណ្ណោះ, ឬលោកនៅមិនជឿស្មោះថា ខ្ញុំមកដណ្តើមយកស្រុកឈើជីវនោះមិនមែនទេ បើខ្ញុំគិតដូច្នោះ ក៏សូមឲ្យទេវតាប្រហារជីវិតខ្ញុំចុះ ។

គូកៀមតបថា ដែលខ្ញុំនឹងលើកស្រុកឲ្យអ្នកនេះ ជាសេចក្តីសុចរិតមិនមែននឹងគិតសង្ស័យអាល័យស្តាយ ឬឧបាយបញ្ឆោតដូចម្តេចក៏ទេ ។ គូកៀមលួងលោមអង្វរប្រគល់ស្រុកឈើជីវឲ្យឡៅពីដូច្នេះ ជាច្រើនដងច្រើនគ្រាណាស់ ឡៅពីនៅមិនព្រមទទួលសោះ ។ បិតុកនិយាយនឹងគូកៀមថា ទ័ពចូចូលើកមកទល់ជិតនឹងកំពែងស្រុកហើយ ឡៅពីបានមកជួយធ្វើការសឹក ហើយលោកគិតទៅប្រគល់ស្រុកឲ្យយូរការដូច្នេះមិនស្រួលទេ ឲ្យលោកខំរិះគិតគ្នាធ្វើការសង្គ្រាមឲ្យសម្រេចសិនសុំគិតប្រគល់ស្រុកទេសឲ្យឡៅពីជាក្រោយចុះ ។

ទៀតនិយាយនឹងតួកៀមថា ខ្ញុំសុំសរសេរសំបុត្រទៅឃាត់ហាមប្អូនឲ្យលើកទ័ពត្រឡប់ទៅវិញ, បើប្អូនមិនស្តាប់សិមគិតលើកកងទ័ពចេញទៅច្បាំងខាងក្រោយ ៗ តួកៀមក៏យល់ព្រមផង ទៀតក៏សរសេរសំបុត្របាត់ឲ្យទាហានកាន់យកទៅឲ្យប្អូនជាច្រើនគ្នា ហើយឲ្យលបយកទៅឲ្យខុងយ៉ុងនឹងគេងតែថា ឲ្យត្រៀមទាហានទុកឲ្យម៉ាំមួនកុំអាលចេញច្បាំង; ទាហានក៏នាំសំបុត្រនោះចេញទៅ ៗ ពួកទាហានប្អូននាំបំរើចូលទៅដល់ប្អូនកងបន្ទាយ, ប្អូនទទួលសំបុត្រមើលឃើញសេចក្តីថា "ទៀតសុំឲ្យពរមកដល់ប្អូន ឲ្យគិតដល់គ្រាដែលនៅធ្វើការជាមួយគ្នានៅគយហៅលោគួន ហើយយើងទាំងសងខាងក៏និពសគ្នាទៅ មិនបានគតប្រទះគ្នាមកទល់នឹងសម័យនេះ ខ្ញុំក៏មានចិត្តគិតដល់អ្នកមិនភ្លេចសោះ; ដែលបិតាអ្នកអនិច្ចកម្មនោះ ព្រោះតៀវឃើប្រទូសរ៉ាយពីខុនរ៉ា តួកៀមមិនមែនទៅចូលរួមគំនិតជាមួយនឹងរ៉ាក់ទេ, ដែលអ្នកមកខឹងនឹងតួកៀមហើយថែមលើកកងទ័ពមកសម្លាប់អស់បណ្តាអ្នកស្រុកដែលនៅទំនេរនោះ ជាសេចក្តីក្តៅក្រហាយខុសឆ្ងាយបាកផ្លូវយុត្តិធម៌ អ្នកក៏ជាមន្ត្រីកងរាជការមានគំរេះប្រាជ្ញាស្រាប់ហើយ គួរឲ្យគិតមើលចុះ សព្វថ្ងៃនេះលីឈុយគុយគីបានជានាហ៊ឺនធំនៅកងស្រុកទៀងហាន់ ព្រះចៅហៀនគេនឹងនាហ៊ឺនមុខមន្ត្រីរាជការ នៅអស់បណ្តាស្រុកមានតែសេចក្តីក្តៅក្រហាយជាច្រើន បំណែកខាងអាណាខែត្រក្រៅក៏នៅកើតពួកចោរផ្លូកក្បាលលឿង តែងតែធ្វើទុក្ខបុកម្នេញ

បណ្ដាក្សត្រជាច្រើនៗ ដោយហេតុមន្ត្រីធំពុំមែនព្រឹត្តសុចរិតធម៌, អ្នកចូរគិតអាណិតដល់បណ្ដាក្សត្រខ្ញុំផងដែលព្រួយទុក្ខ គួរណាស់តែនឹងជួយឧបត្ថម្ភ លើកកងទ័ពទៅបង្ក្រាបពួកអាចោរកំណាច ឲ្យខ្វបង្ខាចតបះគេជះរបស់អ្នក មិនគួរនឹងលើកយកធុរៈជាកិច្ចផ្ទាល់ខ្លួនមកគួនខ្ញុំនឹងតូកៀម ដែលជាមនុស្សស្លូតត្រង់សោះ ពីព្រោះតែបិតារបស់អ្នកសូន្យបង់ជីវិត អ្នកត្រូវគិតឲ្យជាក់ច្បាស់ដោយបញ្ញា បើឃើញថាតូកៀមប្រព្រឹត្តទុច្ចរិតពុំពិតដូចខ្ញុំថាទេ សុំឲ្យអ្នកលើកទ័ពមកចាប់តូកៀមសម្លាប់ចុះ; ដែលខ្ញុំនាំសេចក្ដីមកជំរាបប៉ុណ្ណោះ សូមឲ្យអ្នកឈ្វេងយល់ដល់ទៅខ្ញុំផង" ៗ

ឯចូឆូកាលបានឃើញសេចក្ដីសំបុត្រដូច្នោះ ក៏បណ្ដាលនូវសេចក្ដីក្រោធពិរោធជាពន្លឹក ហើយបែរទៅប្រឹក្សានឹងគុយកៃថា យើ! អាឡៅពីចំជាចិត្តព្រហើនណាស់ ហ៊ានឲ្យសំបុត្រមកហាមឃាត់យើង បើយើងរកទៅហើយឃើញថា វាប្រើឧបាយកលល្បួងបញ្ឆោតយើងមែន នោះគួរតែឲ្យកាត់ក្បាលបំរើដែលកាន់សំបុត្រនេះចេញ ហើយរៀបទ័ពជាប្រញាប់ទៅវាយយកស្រុកឈើជីវឲ្យខានតែបាន ៗ គុយកៃឆ្លើយថា ឡៅពីជាមនុស្សស្លូតត្រង់ជាបំផុត, ដែលនឹងទៅសម្លាប់បំរើកាន់សំបុត្រនោះមិនគួរសោះ សុំឲ្យលោកឆ្លើយតបសំបុត្រទៅយកចិត្តឡៅពីសិន, តទៅមុខសឹមលើកទ័ពទៅវាយយកស្រុកឈើជីវនឹងបានដោយស្រួល ៗ

ប៊ូឆ្កឺយល់ព្រមផងទើបឲ្យឃាត់ខ្លួនបំរើនោះទុក ហើយត្រិះរិះរកសេចក្ដីដែលនឹងធ្វើសំបុត្រតបទៅឡើងវិញ ។

ចំណែកខាងលីថៅ កាលរត់ចេញអំពីលីឈុយគុយគីពីក្រុងតៀងហាន់ទៅដល់ស្រុកឡាំយ៉ុង បានចូលទៅអាស្រ័យនឹងអ្នកស្រុកៗ មិនទទួល; លីថៅក៏ចូលទៅនៅនឹងអ្នកសៀវចៅហ្វាយស្រុកគីជីវ; លីថៅបានធ្វើសេចក្ដីគាប់ប្រសើរទុកដល់អ្នកសៀវមួយគ្រា តែលីថៅធ្វើអាក្រក់ដល់ពួកទាហានស្និទ្ធរបស់អ្នកសៀវៗ ខឹងណាស់ គិតនឹងសម្លាប់លីថៅៗក៏រត់ទៅនៅនឹងគៀវអៀនចៅហ្វាយស្រុកសៀងតុង ។

ឯចាំងស៊ីជានាហ្មឺននៅក្នុងក្រុងទៀងហាន់ ជាមិត្តស្និទ្ធស្នាលនឹងលីថៅ លុះឮថាលីថៅទៅនៅស្រុកសៀងតុង ក៏លបនាំកិរិយាបុត្រនឹងស្ត្រីគ្រប់ក្បាលពួករបស់លីថៅទៅឲ្យលីថៅឯស្រុកសៀងតុង ។ លីឈុយគុយគី ដឹងការបង្គាប់ឲ្យចាប់ចាំងស៊ីសម្លាប់បង់ ហើយធ្វើសំបុត្រទៅដល់គៀវអៀនឲ្យចាប់លីថៅសម្លាប់, លីថៅដឹងខ្លួនក៏រត់ទៅនៅនឹងគៀវមៅចៅហ្វាយស្រុកគាន់លីវ ។

ចំណែកគាន់គុងដែលទៅហាមឃាត់ប៊ូឆ្កឺៗមិនស្ដាប់, គាន់គុងទៅនៅនឹងគៀវបៀវជាប្អូនគៀវមៅនៅស្រុកគាន់លីវនោះ គៀវបៀវក៏នាំគាន់គុងទៅរកគៀវមៅជាបង ។ គាន់គុងជំរាបគៀវមៅថា ប៊ូឆ្កឺបានជាធំនៅខាងប្រជុំខែត្រទិសឯកើតមានសេនាទាហានជាច្រើន ឥឡូវបោលស្រុកគុនជីវ

លើកទៅវាយយកស្រុកឈើដីរ ខ្ញុំយល់ឃើញថាស្រុកគុនដីរនោះគ្មាននរណាមានថ្វីដៃខ្លាំងពូកែនៅរក្សាគ្រប់គ្រងទេ សុំឲ្យលោកចាត់លីប៉ោឲ្យលើកកងទ័ពទៅវាយយកស្រុកគុនដីរ ក៏នឹងបែកបានដោយងាយ, បើបានស្រុកគុនដីរហើយ ស្រុកតាន់លីរនៅខាងទិសឯកើតនេះ ក៏នឹងផុតរួចពីអំណាចចូចូជាប្រាកដ បើនឹងគិតការធំតទៅមុខក៏ស្រួលមិនលំបាក ៗ តៀវមៅបានស្ដាប់ក៏ពេញចិត្ត ទើបចាត់សេនាទាហានឲ្យលីប៉ោជាមេទ័ព ហើយឲ្យយកតាន់ក៊ុងទៅជាមួយ ៗ លីប៉ោលើកកងទ័ពជាប្រញាប់ទៅវាយស្រុកគុនដីរបានហើយ លើកទាហានទន្ទ្រានវាយយកខែត្រខ័ណ្ឌក្បែរផ្លូវទៅដល់ស្រុកប៉ាក់អៀង នៅសល់តែស្រុកអៀងសៀ ១ ស្រុកតងហៃ ១ ស្រុកហ្វូនគ្វន ១ ទាំង ៣ ស្រុកនេះ ជៀយ៉ុកនឹងស៊ុនហ៊ុករក្សាទុកបាន ៗ ឯពោយិនទាហានចូចូដែលនៅក្នុងស្រុកគុនដីរនោះ បែករត់ទៅនឹងទៅរកចូចូ ៗ មានបំរើសេះស្រួតទៅដល់ចូចូមុន យកសេចក្ដីទាំងពួងជំរាបចូចូបានដឹងគ្រប់សព្វ ៗ ចូចូដឹងហើយក៏មានចិត្តបរិវិតក្កណាស់ប្រឹក្សានឹងទាហានទាំងពួងថា ដែលលីប៉ោលើកទ័ពទៅវាយយកស្រុកគុនដីរនោះឃើញថា គ្រប់គ្រួរបស់យើងប្រហែលនឹងវិនាសខ្ចាត់ខ្ចាយអស់ហើយ បើដូច្នេះត្រូវតែយើងលើកកងទ័ពត្រឡប់ទៅច្បាំងនឹងលីប៉ោវិញ ៗ

គុយកៃឆ្លើយថា ដែលលោកនឹងលើកទ័ពត្រឡប់ទៅវិញនោះគួរណាស់ ព្រោះឡៅពីក៏មានសំបុត្រមកឃាត់ហាមលោកផង លោកត្រូវ

មានសំបុត្រតបទៅវិញដើម្បីចងមេត្រីទុកតទៅ សេចក្ដីដែលឡោតិឃាត់ហាមទាំងប៉ុន្មាន លោកក៏បានទទួលស្ដាប់គ្រប់ប្រការរួចសឹមលើកពលសេនាទៅស្រុកគុនដីរ ៗ ចូចបានស្ដាប់ឃើញត្រូវ ក៏ទៅធ្វើសំបុត្រតាមពាក្យគុយកែនិយាយ ហើយប្រគល់ឲ្យទាហានឡោតិនាំទៅ; ចូចក៏លើកទ័ពត្រឡប់ទៅស្រុកគុនដីរ ៗ

បំរើនាំសំបុត្រវិលទៅដល់ស្រុកឈើដីរហើយ ក៏ជូនសំបុត្រនោះឲ្យឡោតិនៅមុខតូកៀម ឡោតិនឹងតូកៀមមើលដឹងសេចក្ដីហើយ ក៏មានអំណរគុណចិត្តណាស់ ៗ តូកៀមឲ្យបំរើទៅអញ្ជើញខុងយ៉ុង ១ គេងដៃ ១ គួនអ៊ូ ១ ជូឡុង ១ ឲ្យចូលមក ហើយពត់ឲ្យរៀបតុលៀងអាហារ អញ្ជើញឡោតិឲ្យអង្គុយក្នុងទីសមគួរហើយទទួលគំនាប់ជំរាបឡោតិថា ខ្លួនខ្ញុំចាស់ជរាហើយ បើនឹងផ្ញើផ្ទុករាជការស្រុកឲ្យបុត្រទាំងពីរក៏ពុំបាន ព្រោះវាគ្មានសតិប្បញ្ញាសោះ ខ្ញុំសូមឲ្យអ្នកទទួលធ្វើជាចៅហ្វាយស្រុកឈើដីរចុះ ឯចំណែកខ្លួនខ្ញុំសុំនៅក្រោមរាជការជួយចាត់ការទំនុកបំរុងតទៅ ៗ ឡោតិបានស្ដាប់តូកៀមនិយាយដូច្នោះ ទើបពិគ្រោះនឹងសេនាទាហានទាំងពួងថា ពីថ្ងៃមុនខុងយ៉ុងបបួលយើងឲ្យមកជួយការពារតូកៀម យើងឃើញថ្វីមេត្រីរាប់អានបានលើកទ័ពមកជួយ ឥឡូវនេះតូកៀមនឹងលើកស្រុកឈើដីរឲ្យដល់យើង បណ្ដារាស្ត្រទាំងអស់បានដឹងក៏នឹងគរហានិន្ទាថា យើងជាមនុស្សលោភចង់បានទ្រព្យនឹងយសសក្ដិ ៗ

បិតុកដំណបទៀតថា  សព្វថ្ងៃនេះកើតចលាចលផ្សេងៗ  ស្រុកទៀងហាក់កាន់តែរៀវរោយទីងសាបសូន្យអស់ហើយ  បើអ្នកឯណាមានសតិប្បញ្ញាក៏ចូរចុះស្លាហ៍ខំរិះគិតក្នុងគ្រានេះចុះ  ឥឡូវនេះតូកៀមព្រមចិត្តស្រះស្រួលលើកស្រុកជូនលោក  ហេតុម្តេចលោកធ្វើកន្តើយព្រងើយដូច្នេះ  ឯស្រុកឈើជីវនេះមានទំណូទៀងក៏ច្រើន  បើទីងប្រមាណអ្នកដែលមានទ្រព្យសម្បត្តិគ្រប់គំបន់  ក៏មានដល់ម៉ឺនរយបាយ  លោកចូរទទួលយកចុះទីងបានគិតការតទៅ ។  ទៀតតីឆ្លើយថា  អ្នកកុំបង្ខំឡើយ យើងមិនទទួលយកទេ ។

តាន់តេងនិយាយទីងទៀតតីថា  តូកៀមនេះជាមនុស្សជកមានពេកមែន, លោកចូរគោណិតដល់ក្រស្តទាំងពួង  ព្រមទទួលយកស្រុកឈើជីវទៅ ។ ទៀតតីឆ្លើយថា  អ្នកសៀវបៅហ្វាយស្រុកឈើជីវនោះ  ជាតួជនាហ្នឹងតមក ៤ ដំណមនុស្សហើយៗ មានស្រុកទៀងជាច្រើន  ហេតុម្តេចអ្នកមិនលើកស្រុកនេះឲ្យ ។

ខុងយ៉ុងឆ្លើយថា  អ្នកសៀវនោះឧបមាដូចជាសពនៅក្នុងស្នូប  ពប់តែថ្ងៃខែដែលទីងព្រោមទៅវិញ  ទាំងសតិប្បញ្ញាក៏មិនសូវមាន  ទីងកប់គានឲ្យធ្វើជាធំតទៅដូចម្តេចបាន;  ឥឡូវបុណ្យមកដល់ហើយ  ហេតុម្តេចលោកមិនព្រមទទួល ។  ទៀតតីក៏នៅតែមិនព្រមទទួលសោះ ។

តូកៀមបានព្លទៀតតីបេះតែប្រកែក  ក៏ស្រែកទួញយំថា  បើអ្នកមិនទទួលធ្វើចៅហ្វាយស្រុកនេះទេ  ហាក់បីដូចជាអ្នកគ្មានមេត្តាខ្ញុំសោះ

ឡើយ បើកាលណាខ្ញុំនឹងស្លាប់ក៏មិនបានស្លាប់ទៅដោយស្រួល ព្រោះរំជួលកន្ទួលនឹងរឿងនេះ ។

កូនអ៊ុំ គៀវហ៊ុយនិយាយនឹងឡោពីទៀតថា គូកៀមព្រមប្រគល់ស្រុកឲ្យលោកដោយសុចរិត ហេតុម្តេច លោកមិនអាណិត ទាល់តែកើតទោមនស្សយ៉ាងនេះ? ។ ឡោពីក៏នៅតែមិនព្រមទទួលទៀត ។

គូកៀមនិយាយថែមទៀតថា បើអ្នកមិនព្រមទទួលធ្វើជាចៅហ្វាយស្រុកនេះ ចូរត្រិះរិះអាណិតទៅនៅរក្សាស្រុកសៀវដាយចុះ ស្រុកនោះក៏ឡើងស្តាប់បង្គាប់ស្រុកឈីជីរនេះ បើខ្ញុំមានទុក្ខក្តៅក្រហាយវេលាណា នឹងបានពឹងពាក់អាស្រ័យនឹងអ្នកផង ។ មនុស្សទាំងពួងដែលនៅជួបជុំក្នុងទីនោះ បាននាំគ្នាជួយនិយាយអង្វរឲ្យឡោពីទទួលយកស្រុកសៀវដាយ ។ គូកៀមមានសេចក្តីត្រេកអរណាស់ ទើបយកមាសប្រាក់សំពត់អាវមកចែកឲ្យឡោពីនឹងទាហានខ្ទង់យ៉ុង តេងកៃជាច្រើន ។

ក្នុងពេលនោះ ជូឡុងនិយាយនឹងឡោពីថា លោកមកជួយទុក្ខធុរៈគូកៀមឃើញថាសម្រេចហើយ ខ្ញុំនឹងសុំលាលោកទៅរកកងស៊ុនថានវិញ ។ ឡោពីក៏ហើយចាប់ដៃជូឡុងជាប់ ហើយនិយាយផ្តែផ្តាំគ្នាជាអនេកប្រការ ។ ជូឡុងក៏លាឡោពីប្រមូលទាហាន ២ ពាន់លើកចេញទៅស្រុកប៉ាក់ពេង ។

ឯខ្ទង់យ៉ុងនឹងតេងកៃ ក៏លាឡោពីនឹងគូកៀមលើកទាហានចេញទៅកាន់ស្រុករៀងខ្លួន ។ គូកៀមធ្វើសំបុត្របើកខែត្រពាក់ឲ្យជូនដំណើរ

ទៀតពីទៅឈរក្បែរស្រុកនេះផ្សេង ៗ កាលទៀតពីទៅឈរក្បែរស្រុកនោះ បណ្តាពស្រ្តីទាំងឡាយពេះពយស្រឡាញ់ទៀតពីជាច្រើន ៗ

កាលចូច្ចូលើកទ័ពទៅដល់កណ្តាលផ្លូវបានប្រទះនឹងហោយិនៗ ដំពបឱ្យការណ៍ថា លីប៉ោ៉ដែលជាមេទ័ពលើកមកនោះ រូបកាយធំដំបងទ្រង់ទ្រាយជាអ្នកមានកម្លាំងខ្លាំងពូកែ បានតាន់កុងតាំងទុកជាទីប្រឹក្សា លុះពយបានស្រុកគុនជីវហើយ ក៏លើកចូលទៅពយស្រុកក្បែរផ្លូវរៀងទៅដល់ស្រុកប៉ាក់អៀង, ឯស៊ុនហុកនឹងគៀយ៉ុកត្រូវលីប៉ោ៉ចាត់ឱ្យនៅរក្សាស្រុកទុកទាំង ៣ តំបន់ ៗ ចូច្ចូបានស្តាប់ហើយឆ្លើយតបថា "លីប៉ោ៉នោះជាអ្នកមានថ្វីដៃខ្លាំងពូកែពិតមែនហើយ តែមិនជាអ្នកស្ទាត់ក្នុងការទាំងពួងទេ អ្នកកុំបីជាទុក្ខឡើយ" លុះនិយាយគ្នាហើយ ក៏ឱ្យស្រូតលើកទាហានទៅដល់ស្រុកតេងកួន ហើយឱ្យឈប់តាំងបន្ទាយជាមាំមួនក្នុងទីនោះ ៗ

ឯលីប៉ោ៉កាលឮកិត្តិសព្ទថា ចូច្ចូលើកទ័ពទៅតាំងបន្ទាយនៅស្រុកតេងកួនដូច្នោះ ទើបចាត់ឱ្យលីហងនឹងស៊ុឡាន់យុំទាហានមួយហ្មឺនទៅនៅរក្សាស្រុកគុនជីវ ៗ តាន់កុងបានឮដូច្នោះ ក៏សួរលីប៉ោ៉ថា ស្រុកគុនជីវនេះជាទីសំខាន់ លោកនឹងឱ្យលីហងនឹងស៊ុឡាន់ទៅនៅរក្សានោះ តើខ្លួនលោកនឹងទៅនៅឯណា? ៗ លីប៉ោ៉ឆ្លើយថា យើងនឹងលើកទៅតាំងទល់ទ័ពចូច្ចូឯស្រុកប៉ាក់អៀង ប្រយោជន៍នឹងបានការពារស្រុកទុកឱ្យធំទូលាយ ។ តាន់កុងថា លោកនឹងទុកចិត្តឱ្យលីហងនឹងស៊ុឡាន់

នៅក្បែរស្រុកគុនដីវ ខ្ញុំយល់ឃើញថា មុខជាចាញ់ប្រៀបតែម្តង ព្រោះភ្នំថៃសាន់នៅទិសឯត្បូងស្រុកគុនដីវនោះ ចម្ងាយប្រហែល ៨០០ សិន (៣២, គ.ម.) មានច្រកបំពោះចុះតែជើងអ្នកមួយ ដើរតាមចន្លោះភ្នំជាផ្លូវកាត់ឲ្យត្រង់ គង់តែបូឆូនឹងស្រុកលើកត្រម៉ង់តាមផ្លូវនោះមក សុំឲ្យលោកចាត់ទាហានមួយម៉ឺនទៅបង្កប់ចាំនៅសងខាងច្រកភ្នំនោះ បើកងទ័ពមុខបូឆូលើកមកដល់ទីនោះ ត្រូវឲ្យអស់ទាហានសម្ងំស្ងាត់ បើកាលណាបូឆូលើកមកដល់ សឹមឲ្យលើកចេញស្កាត់ខ្ទប់ទាំងសងខាង កងទ័ពមុខនៃបូឆូនឹងត្រឡប់វិលទៅជួយក៏មិនទាន់ ដូច្នេះឃើញថានឹងចាប់បូឆូបានដោយងាយ ។

លីប៉ោបានស្ដាប់ឆ្លើយតបថា "ដែលយើងនឹងតាំងកងទ័ពបូឆូទៅស្រុកប៉ាក់អៀងនោះ សេចក្ដីគិតរបស់យើងឃើញថា មានផ្លូវនឹងតតាំងប្រាំងគ្នាជាច្រើនកន្លែង មិនបាច់នឹងបែងទាហានទៅបង្កប់ក្នុងទីនោះនាំឲ្យតែរវល់ទេ" ថាហើយលីប៉ោក៏ចាត់បែងទាហានត្រៀមទុកតទ័ពផ្ទាប់ស្រុកប៉ាក់អៀង ។

បូឆូដឹងដំណឹងច្បាស់ ក៏គិតស្រឡះលើកទាហានទៅតាមច្រកផ្លូវភ្នំថៃសាន់ ។ គុយកែគិតទាន់ឃាត់ហាមបូឆូថា ទីភ្នំថៃសាន់នោះមានបំពោះតែផ្លូវដើរ ខ្លាចលីប៉ោទៅបង្កប់ទាហាននៅទីនោះ ហេតុនេះសុំឲ្យលោកឈប់បង្អង់សិន ចាំឲ្យបំរើសេះទៅស៊ើបល្បាតមើល ។

(មានត)

# ព្រះរាជពង្សាវតារប្រទេសកម្ពុជា

## ភាគទី ២

### សម័យនគរធំ

### ឧកញ៉ាវេទពិទូរ ឈឹម - ក្រសេម រៀបរៀង

(តទៅ)

## (រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧)

តែបើមើលព្រះរាជពង្សាវតារក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី ១ ក៏នឹងឃើញថា ព្រះបាទយសោវរ្ម័នជាអ្នកសាងក្រុងនគរធំ ឲ្យឈ្មោះថា "ស្រីយសោធរបុរៈ", សាងប្រាសាទកណ្ដាល ឲ្យឈ្មោះថា "យសោធរគិរី", សាងប្រាសាទទេវស្ថាន ១ នៅលើភ្នំបាខែង ឲ្យឈ្មោះថា "យសោធរេស្វរៈ", សាងស្រះធំ ១ ក្រៅកំពែងក្រុង ឲ្យឈ្មោះថា "យសោធរតដាក" ។ ឈ្មោះទាំងនេះ ឃើញសុទ្ធតែភ្ជាប់ព្រះនាមរបស់ព្រះអង្គផង, ព្រោះហេតុដូច្នេះ ប្រាសាទយសោធរគិរី គេទើបយល់ថា ព្រះបាទយសោវរ្ម័នទ្រង់សាងជាដំបូងជាប្រាកដ ។ ឯរឿងដែលថា ព្រះបាទយសោវរ្ម័នទ្រង់កាន់តែសាសនាព្រាហ្មណ៍នោះ ក៏មិនពិតដូច្នោះទាំងអស់ទេ ព្រោះប្រាកដថា ទ្រង់បានសាងវត្តក្នុងព្រះពុទ្ធសាសនា ១ ឲ្យឈ្មោះថា "សោគតាស្រម" ។ តាមសេចក្ដីនេះ គួរឲ្យយល់ថា ទ្រង់កាន់ទាំងសាសនាព្រាហ្មណ៍ទាំងព្រះពុទ្ធសាសនា ។

ភាពផែនទី ក្រុងយសោធរបុរៈនោះ មានលក្ខណៈដែលនាំឲ្យយើងយល់ឃើញយ៉ាងជាក់លាក់ថា ទ្រង់ធ្វើជាតំណាងពិភពលោកទាំងមូល ដោយគ្រាន់តែបង្រួមឲ្យតូចចុះប៉ុណ្ណោះ គឺប្រាសាទយសោធរគិរី (បាយ័ន) តាំងនៅចំកណ្ដាលផ្ចិតក្រុងនោះ ជាតំណាងភ្នំព្រះសុមេរុ ដែលតាំងនៅកណ្ដាលលោក, កំពែងជុំវិញក្រុង ជាតំណាងកណ្ដាបចក្រវាឡ, គូរជុំវិញកំពែង ជាតំណាងមហាសមុទ្រ ដែលនៅអមលោកទាំងមូល ។ ការធ្វើព្រះបរមរាជវាំងបែបនេះ រាប់ថាជារាជប្រវេណីរបស់ព្រះមហាក្សត្រិយ៍ខ្មែរ, សឹងមានមកតាំងពីបុរាណកាល, បើយើងពិនិត្យមើលលក្ខណៈកសាងព្រះរាជនិវេសន៍នៅឥណ្ឌា ក៏មានទំនងដូចគ្នានេះដែរ ។

ប្រាសាទយសោធរគិរី ក្រៅអំពីជាតំណាងភ្នំព្រះសុមេរុហើយ គឺជា "គារវស្ថាន", ប្រាកដតាមព្រះរាជពង្សាវតារក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី ១ ថា ប្រាសាទនេះជាទីប្រតិស្ឋានរូបព្រះកម្រតែងជគតរាជ (រូបសិវលិង្គមាស) ដែលជាអទេ្យាផ្ទៃក្រោម, ។ មកក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី៧ នេះ ប្រាកដថា ជាទីប្រតិស្ឋានព្រះពុទ្ធរាជ (ព្រះពុទ្ធរូបជាតំណាងអង្គព្រះបាទជយវរ្ម័ន) ដែលជារាជសារៈឥទេ្យាផ្ទៃក្រោមហើយទឹងជាទីប្រតិស្ឋានព្រះបរមបិតរ (គឺព្រះបរមអដ្ឋិនៃព្រះមហាក្សត្រិយ៍ទាំងឡាយ) ។ ដូច្នេះ គប្បីដឹងថា ទីនេះជាទីគោរពរបស់ព្រះមហាក្សត្រិយ៍ទាំងឡាយក្នុងសម័យនគរធំ ។ មុខ ៤ នៅកំពូលកណ្ដាលនោះ ជាគ្រឿងសំដែងព្រហ្មវិហារធម៌របស់ព្រះមហាក្សត្រិយ៍ ។

**រាជាភិសេក** — វេលាកន្លងមក ៤ ឆ្នាំ រាប់ពីឆ្នាំដែលព្រះបាទជយវរ្ម័នទ្រង់បានកម្រាបពួកខ្មាំង និង បានគ្រងរាជបល្ល័ង្ក គឺមកក្នុងឆ្នាំ ព.ស. ១៧២០ ប្រទេសកម្ពុជាបានដល់នូវសេចក្ដីសុខក្សេមក្សាន្តហើយ ទើបទ្រង់ត្រាស់ព្រះរាជបញ្ជា ឲ្យធ្វើព្រះរាជពិធីបរមរាជាភិសេកនៅក្រោមឆ័ត្រជ័យ តាមខត្តិយរាជប្រវេណី ព្រមទាំងធ្វើពិធីសម្ពោធក្រុងស្រីយសោធរបុរៈ ដែលទ្រង់បានបដិសង្ខរណ៍ឡើងជាថ្មី ក្នុងរវាង ៤ ឆ្នាំនោះផង ។ ព្រះបរមរាជវាំងយសោធរបុរៈក្នុងវេលានោះ ពេញទៅដោយសេចក្ដីល្អនិងរុងរឿងហាក់ដូចជាឋានសួគ៌ ។

ក្រោយដែលធ្វើព្រះរាជពិធីបរមរាជាភិសេកហើយ ព្រះបាទជយ-វរ្ម័នបានចាប់កសាងតទៅទៀតនូវប្រាសាទសិលាជាច្រើន នៅតំបន់នគរធំ រៀងទៅតាមបន្ទល់គ្នា គឺប្រាសាទដែលហៅតាមពាក្យសាមញ្ញថា: តាព្រហ្ម, បន្ទាយក្ដី (បន្ទាយកុដិ), ព្រះខ័ន, នាគព័ន្ធ, តាសោម, ក្រោលគោ, តានៃ ។ ក្រៅពីនេះ ទ្រង់បានសាងនៅខេត្តក្រៅខ្លះទៀត ។ តាមដែលបានដឹងក្នុងវេលានេះ ប្រាសាទបន្ទាយឆ្មារ នៅខាងទិសពាយ័ព្យនៃប្រាសាទវត្តនគរក្នុងខេត្តកំពង់ចាម្ប៍ និងប្រាសាទតាព្រហ្ម នៅក្នុងខេត្តបាទី ។ ប្រាសាទអំបាលនេះ ទ្រង់សាងឡើងដើម្បីអ្វី? ។ តាមភាពរបស់ប្រាសាទ និងតាមសិលាចារឹកខ្លះ អាចជាគ្រឿងបញ្ជាក់ ឲ្យយើងដឹងបានខ្លះថា: -

ប្រាសាទតាព្រហ្ម - នៅខាងកើតនគរធំ មានសិលាចារឹកសំដែងថា សាងឡើងក្នុងឆ្នាំ ព.ស. ១៧២៩ សម្រាប់ប្រតិស្ឋានព្រះបរមរូបនៃព្រះវររាជជននីរបស់ព្រះអង្គ ដែលលើកឡើងជា ព្រះប្រជ្ញាបារមិតា និងរូបសម្តេចព្រះគ្រូ ព្រមទាំងព្រះរូបឯទៀតចំនួន ២៦០ រូប ហើយទ្រង់ដាក់គ្រឿងដង្វាយថ្វាយនៅក្នុងប្រាសាទនេះ គឺបានជាមាស ១ ទម្ងន់ជាង ៥០០០ គីឡូក្រាម (បើតាមដំឡៃសព្វថ្ងៃ ប្រមាណ ១០ លានរៀល ឬជាង ១០ លានរៀល) និងបានជាមប្រាក់ដ៏មានទម្ងន់ស្មើគ្នានេះ ១ ទៀត, ពេជ្រទាំងគ្រាប់ធំ ៣៥ គ្រាប់, ត្បូងមុក្តា ៤០.៦២០ គ្រាប់, ត្បូងយ៉ាងល្អបែបឯទៀត ៤.៥៤០ គ្រាប់, ផ្តិលមាសយ៉ាងធំ ១, នាំងស្រុកបិន ៩៦៧, ក្រែគ្រឿងដោយសំពត់ព្រែ ៥១២, កូស ៥២៣ ។ ផ្នែកស្បៀងអាហារក៏មានគ្រប់យ៉ាង គឺអង្ករ បើរ ទឹកដោះគោ ស្ករក្រាម ប្រេង គ្រាប់ផលានុផលផ្សេងៗដែលសម្រាប់ប្រើការបូជាពល់ថ្ងៃ និងរបស់ដែលប្រើបូជាក្នុងថ្ងៃពិធីបុណ្យជាពិសេស គឺគ្រាប់ផលានុផល បើរ ទឹកដោះគោ ទឹកឃ្មុំប្រេង ក្រមួនខ្ទឹមបទូន៍ កប្បូរ គ្រឿងចីវរ ២.៣៨៧ គូ ។ របស់ទាំងនេះសម្រាប់ថ្វាយព្រះរូបទាំងអស់ មានបញ្ជីដែលឃ្លាំងត្រូវបើកចំណាយឲ្យរៀងរាល់ឆ្នាំ ។ ទ្រង់តែងតាំងភ្នាក់ងាររាជការ ជាអ្នកត្រួតត្រានៅក្នុងប្រាសាទនេះ

ទីងអ្នកបំរើការ - ភូមិចំណុះ គឺមនុស្សអ្នកធ្វើការថែរក្សាប្រាសាទនេះចំនួន ៧៩.៣៦៥ នាក់ អ្នកនៅផ្ទាល់ក្នុងកំពែងប្រាសាទចំនួន ១២.៦៤០ នាក់, មានភូមិចំណុះប្រាសាទនេះចំនួន ៣ ១៤០ ភូមិ ។ ក្នុងមនុស្សអំបាលនេះ មានអធិការ ៨ នាក់, មានមេគណ ២.៧៤០ នាក់, អ្នកគាល់បំរើព្រះបរមរូបផ្ទាល់ ២.២០២ នាក់, មានស្រ្តីរបាំ ៦១៥ នាក់ សម្រាប់លេងរបាំថ្វាយជាអាចិណ្ណ ។

ការដែលព្រះបាទជយវរ្ម័ន ទ្រង់បំពេញបុណ្យកិរិយាវត្តទាំងប៉ុន្មាននេះ ដោយទ្រង់មានសេចក្ដីគោរព ក្នុងព្រះវរជននីជាយ៉ាងក្រៃលែង ។ ក្នុងបុងសិលាចារិកមានសេចក្ដីប្រណិធាន សូមឲ្យព្រះមាតារបស់ខ្ញុំបានសម្រេចនូវការៈជាព្រះពុទ្ធទៅអនាគត ។

**ប្រាសាទបន្ទាយក្ដី** ជាវត្ត ឬជាធម្មសភា ក្នុងព្រះពុទ្ធសាសនាលទ្ធិមហាយាន ។ គេសង្កេតឃើញរូបភាពក្នុងរឿងពុទ្ធប្រវត្តិជាច្រើនអន្លើ ។

**ប្រាសាទនាគព័ន្ធ** ពីដើមប្រហែលជាឲ្យឈ្មោះថា ស្រះអនោ-តត្ត, តែសព្វថ្ងៃនេះគេហៅថា ប្រាសាទនាគព័ន្ធ តាមដែលរូបនាគព័ន្ធព័ន្ធប្រាសាទដែលនៅកណ្ដាលស្រះនោះ ។ ស្រះនេះគឺគេធ្វើតំណាងស្រះអនោតត្ត ដែលមានរឿងដំណាលថា នៅក្នុងព្រៃហិមពាន្ត ទឹកស្រះនេះគេនិយមថា មានសព្វគុណសក្ដិសិទ្ធិអស្ចារ្យ មានផ្លូវហូរចេញទៅតាម

ក្បាលមនុស្ស ក្បាលកជសីហ៍ ក្បាលដំរី និងក្បាលគោ ដំមាននៅក្នុងគ្រឹះទាំង ៤ ទិស, អ្នកសញ្ចរទៅមករមែងទៅងូតទឹកជំរះមន្ទិលនៅទីនោះ ។

**ប្រាសាទព្រះខ័ន** នៅមិនទាន់ដឹងច្បាស់ថា សាងឡើងសម្រាប់អ្វី តែមិនមែនសម្រាប់ដំកល់ព្រះខ័ន ដូចអ្នកខ្លះយល់នោះទេ ។ តាមផ្លូវសន្និដ្ឋានឃើញថា ជាស្ថានក្នុងព្រះពុទ្ធសាសនា ប្រហែលគ្នានឹងបន្ទាយក្តី ។ ប្រាសាទតូចៗ ដែលនៅរៀងតាមថ្នល់ថ្លានោះ ជាទីសំចតរបស់ប្រជាជនដែលសញ្ចរទៅមក ។

**ប្រាសាទបន្ទាយឆ្មារ** នៅវត្តនគរ (កំពង់ចាម្ស) ទ្រង់សាងទុកអនុស្សាវរីយ៍ទីរឭកដល់គុណបំណាច់ របស់ព្រះរាជកុមារព្រះនាមស្រីន្ទ្រ-កុមារ(១) (លាក់ទយេស) ជាព្រះរាជបុត្ររបស់ព្រះអង្គនិងសេនា ៤ នាក់ទៀត ដែលជាគៀនចំបាំងជាមួយគ្នា គឺច្បាំងក្រាបភរតរាហុ ក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី ២ និង ច្បាំងក្រាបចាម្ស ក្នុងកាលក្រោយៗមក ។

**ប្រាសាទតាព្រហ្ម** នៅបាទី នៅមិនទាន់ដឹងច្បាស់ថា សាងឡើងសម្រាប់អ្វី ។ (មានត)

---

១ ក្នុងសិលាចារឹកព្រះបាទយសោវរ្ម័នទី ២ ថាព្រះរាជកុមារនេះព្រះនាម ស្រីឥន្ទ្រកុមារ ។

# បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

## របស់ក្រសួងធម្មការ

(តទៅ)

---

សញ្ញាប័ត្រលេខ ៧៣៦ ចុះថ្ងៃពុធ ៣ កើតខែមិគសិរ ឆ្នាំឆ្លូវឯកស័ក ព. ស. ២៤៩២ តាំងលោកគ្រូ ប៉ែន-វៀល នាមធាយា ធម្មត្ថេរ កើតឆ្នាំរោង អាយុ ៧០ វស្សា ១៩ ជាគ្រូសូត្រឆ្វេងវត្ត-ឃុំ-ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៧៣៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហាយ-យ៉ន នាមធាយា ធម្មជោត កើតឆ្នាំឆ្លូវ អាយុ ៣៧ វស្សា ១៦ ជាគ្រូសូត្រស្តាំវត្តបុប្ផាសុវណ្ណ ឃុំអន្លង់ត្នោត ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៧៣៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទន់-ខាន់ នាមធាយា និលសុវណ្ណ កើតឆ្នាំឆ្លូវ អាយុ ៣៧ វស្សា ១៦ ជាគ្រូសូត្រឆ្វេងវត្ត-ឃុំ-ស្រុកខែត្រ-ដដែល ។

សញ្ញាប័ត្រលេខ ៧៣៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទិត-ញឹម នាមធាយា ធម្មសុវណ្ណ កើតឆ្នាំឆ្លូវ អាយុ ៣៧ វស្សា ១៥ ជាគ្រូសូត្រស្តាំវត្តបន្ទាយក្រោម ឃុំបឹងកន្ទួត ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៧៤០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សេក-អឿន នាមធាយា ព្រហ្មត្ថេរ កើតឆ្នាំមមី អាយុ ៣២ វស្សា ១២ ជាគ្រូសូត្រឆ្វេងវត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៧៤១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កេត-គាត នាមធាយា ព្រហ្មគ្រោះ កើតឆ្នាំរកា អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្តរតនវង្ស ឃុំក្បាលត្រាច-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៤២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជ័យ-ឆៃ នាមធាយា បញ្ញាវិន័យ កើតឆ្នាំ... អាយុ ២៧ វស្សា ៨ ជាគ្រូសូត្រឆ្វេងវត្ត ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៤៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឃិន-ឆៃ នាមធាយា ធម្មគ្រោះ កើតឆ្នាំ... អាយុ ៣៤ វស្សា ១៤ ជាគ្រូសូត្រស្តាំ វត្តកំបលមហាព្រហ្ម ឃុំ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៤៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ាក់-ឃិន នាមធាយា បទុមគ្រោះ កើតឆ្នាំរក អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រឆ្វេងវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៤៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-នៅ នាមធាយា គន្ធជោត កើតឆ្នាំម្សាញ់ អាយុ ៤៥ វស្សា ២៥ ជាគ្រូសូត្រស្តាំ វត្តសម្តេចយស ឃុំស្នាអន្សា ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៧៤៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-ប៉ាច នាមធាយា ព្រហ្មសុវណ្ណ កើតឆ្នាំមមែ អាយុ ៤៣ វស្សា ២៣ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

(មានត)